# បេឡាជាតិរបបសន្តិសុខសង្គម

# National Social Security Fund

# របាយការណ៍

# ស្តីពី

# លទ្ធផលការងារសម្រេចបានឆ្នាំ២០១៤
# និងទិសដៅអនុវត្តបន្តរបស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត

# (ស.ផ.គ)




## ថ្ងៃនេះ ថ្ងៃស្អែក កុំឲ្យមានគ្រោះថ្នាក់ចរាចរណ៍

គ្រោះថ្នាក់ចរាចរណ៍ គឺជាមហន្តរាយមួយដែលបានបណ្តាលឲ្យមានមនុស្សស្លាប់ របួស ឬពិការ និងធ្វើឲ្យខូចខាតទ្រព្យសម្បត្តិរដ្ឋ និងឯកជនជាច្រើន

## ចំណាប់អារម្មណ៍ ពីប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត

បច្ចុប្បន្នគ្រោះថ្នាក់ចរាចរណ៍ ជាកង្វល់ដ៏ធ្ងន់ធ្ងរដល់រាជរដ្ឋាភិបាល ដោយសារជនរងគ្រោះបានបាត់បង់ជីវិត របួស ពិការ ខូចខាតទ្រព្យសម្បត្តិរដ្ឋ និង ឯកជនយ៉ាងច្រើន ជាពិសេសកម្មករ-កម្មការិនី ដែលទទួលរងគ្រោះថ្នាក់ចរាចរណ៍ពេលកំពុងធ្វើដំណើរទៅ និង ត្រឡប់មកពីបំពេញការងារ ដោយមធ្យោបាយនានា ។ គ្រោះថ្នាក់ចរាចរណ៍បណ្តាលមកពី បើកបរហួសល្បឿនកំណត់ បើកបរក្នុងស្ថានភាពស្រវឹង មិនគោរពសិទ្ធិអាទិភាព ជែងក្នុងស្ថានភាពគ្រោះថ្នាក់ មិនប្រកាន់ស្តាំ និង បើកបរខ្វះការអធ្យាស្រ័យគ្នាជាដើម ។

ដើម្បីចូលរួមកាត់បន្ថយ ក៏ដូចជាទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិតហៅកាត់ថា "ស.ផ.ក" បានបង្កើតឡើងដោយសេចក្តីសម្រេចលេខ ០០២/១៣ ក.ប/ស.ស.រ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ដែលមានសមាសភាពមកពីក្រសួង និង ស្ថាប័នពាក់ព័ន្ធ ។ បានរៀបចំផែនការការងារ និង សម្ភារឧបទ្ទេសសម្រាប់ផ្សព្វផ្សាយអប់រំដល់អ្នកបើកបរដឹកកម្មករ និយោជិត កម្មករ-កម្មការិនី ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក, បច្ចេកទេសត្រួតពិនិត្យយានយន្ត, វិជ្ជាសង្គ្រោះបឋម, ពាក់មួកសុវត្ថិភាព និង វិធីការពារគ្រោះថ្នាក់ផ្សេងៗ ជាពិសេសចំណុចក្តៅដែលបណ្តាលឱ្យគ្រោះថ្នាក់ចរាចរណ៍ជាញឹកញាប់ ។ លើសពីនេះទៅទៀត អគ្គស្នងការនគរបាលជាតិ និងក្រសួងសាធារណការ បានផ្តល់កិច្ចសហការ សម្របសម្រួល រៀបចំប្រជុំផ្សព្វផ្សាយអប់រំ ប្រឡង និងផ្តល់ប័ណ្ណបើកបរ តាមបណ្តារាជធានី/ខេត្ត ជាមួយក្រុមការងារ ស.ផ.ក ព្រមទាំងមានការចូលរួមពី ស្ថាប័ន អង្គការ វិស័យឯកជន និងសាធារណជន ដែលពាក់ព័ន្ធ ហើយក៏មានការចូលរួមពីអ្នកប្រើប្រាស់ផ្លូវយ៉ាងសស្រាក់សស្រាំ ក្នុងការគោរពច្បាប់ចរាចរណ៍ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ស្របគ្នានឹងសេចក្តីអំពាវនាវស្តីពីការចូលរួមគាំទ្រ និង អនុវត្តសកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោករបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក នូវវិធាន ១០ ចំណុចដើម្បីសុវត្ថិភាពចរាចរណ៍ផ្លូវគោកដូចដែលមានចែងខាងក្រោម៖

១- ពាក់មួកសុវត្ថិភាព និង ខ្សែក្រវាត់សុវត្ថិភាពឱ្យបានត្រឹមត្រូវរាល់ពេល ទាំងអ្នកបើកបរ និងអ្នករួមដំណើរតាមទោចក្រយានយន្ត និង រថយន្តទោះជិត ឬឆ្ងាយ

២- បើពិសាគ្រឿងស្រវឹង កុំបើកបរ

៣- កុំបើកបរហួសល្បឿនកំណត់

៤- កុំវ៉ា(ជែង)ក្នុងស្ថានភាពគ្រោះថ្នាក់

៥- កុំធ្វើដំណើរតាមយានយន្តផ្ទុកលើសចំណុះកំណត់

៦- គោរពសិទ្ធិអាទិភាពពេលបើកបរ និង បើកបរចេះអធ្យាស្រ័យ

៧- កុំប្រើទូរស័ព្ទដៃក្នុងពេលកំពុងបើកបរ

៨- ត្រួតពិនិត្យយានយន្ត និង គ្រឿងបរិធានមុនពេលបើកបរ ឬធ្វើដំណើរ

៩- ត្រូវមានប័ណ្ណបើកបរត្រឹមត្រូវតាមប្រភេទយានយន្ត

១០- ត្រូវមានសម្ភារចំណាំងផ្លាតនៅលើខ្លួន ឬយានយន្ត នៅពេលធ្វើដំណើរពេលយប់នៅកន្លែងដែលគ្មានភ្លើងបំភ្លឺ ។

ក្រុមការងារ ស.ផ.ក សូមអំពាវនាវដល់អ្នកប្រើប្រាស់ផ្លូវគ្រប់ៗរូប ចូលរួមទប់ស្កាត់ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍តាមរយៈការគោរពច្បាប់ចរាចរណ៍ផ្លូវគោក និងអនុវត្តនូវវិធាន ១០ ចំណុច របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកឲ្យបានខ្ជាប់ខ្ជួន។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៤

# មាតិកា


សេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត ........ i
ពាក្យសរសេរសង្ខេប........ iv
ប្រវត្តិរូប និងបទពិសោធន៍ការងាររបស់ក្រុមការងារ ស.ផ.ក........ v
របាយការណ៍បូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្តរបស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត........ ១
១-ស្ថានភាពចរាចរណ៍ក្នុងប្រទេសកម្ពុជា........ ៣
១-១-ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ឆ្នាំ២០១៤........ ៣
១-២-មូលហេតុគ្រោះថ្នាក់ចរាចរណ៍ឆ្នាំ២០១៤........ ៤
២-គ្រោះថ្នាក់ចរាចរណ៍កម្មករនិយោជិត (គ្រោះថ្នាក់ការងារ) ឆ្នាំ២០១៤........ ៥
២-១-ស្ថានភាពគ្រោះថ្នាក់........ ៥
២-២-មូលហេតុគ្រោះថ្នាក់........ ៧
៣-លទ្ធផលការងារសម្រេចបាន........ ៩
៣-១-ប្រជុំវិសាមញ្ញ ........ ៩
៣-២-ផ្សព្វផ្សាយអប់រំដល់អ្នកបើកបរដឹកកម្មករនិយោជិត........ ១៧
៣-៣-ប្រៀបធៀបទិន្នន័យអំពីអ្នកបើកបរឆ្នាំ២០១៣ និងឆ្នាំ២០១៤........ ២២
៣-៤-សិក្ខាពីអ្នកបើកបរ និងតំណាងរោងចក្រ........ ២៥
៣-៥-ផ្សព្វផ្សាយអប់រំដល់និយោជក នាយក ម្ចាស់ ឬតំណាង សហគ្រាស គ្រឹះស្ថាន... ២៨
៤-បញ្ហាប្រឈម........ ៣១
៥-ដំណោះស្រាយ........ ៣២
៦-ទិសដៅអនុវត្តបន្ត ........ ៣៣
៧-លទ្ធផលរំពឹងទុក........ ៣៤
៨-សេចក្តីសន្និដ្ឋាន........ ៣៥
៩-ឯកសារយោង........ ៣៦
១០-ទំនាក់ទំនងផ្ទាល់........ ៣៧

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :..........០០៤/១៦..........ក.ប/ស.ស.រ

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលសមាសភាពក្រុមការងារ
# សុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត
# នៃបេឡាជាតិរបបសន្តិសុខសង្គម

## ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ រៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងសេចក្តីសម្រេចលេខ ០០២/១៣ ប.ក/ស.ស.រ ចុះថ្ងៃទី២៥ ខែ មករា ឆ្នាំ ២០១៣ ស្តីពីការបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

# សម្រេច

**ប្រការ ១.-** ត្រូវបានកែសម្រួលសមាសភាពក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិរបបសន្តិសុខសង្គម ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១.លោក អ៊ុក សមវិទ្យា | នាយកបេឡាជាតិរបបសន្តិសុខសង្គម<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២.លោក ព្រាប ច័ន្ទវិបុល | ប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក<br>នៃក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣.ឧត្តមសេនីយ៍ត្រី លុយ ឈីន | អនុប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់<br>នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤.លោកវេជ្ជបណ្ឌិត នាង ភារិទ្ធ | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ<br>នៃក្រសួងសុខាភិបាល | អនុប្រធាន |
| ៥.លោក ហុក ហួលីម | នាយកទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស<br>នៃសាលារាជធានីភ្នំពេញ | សមាជិក |
| ៦.លោកវរសេនីយ៍ត្រី ម៉ក់ ណារិទ្ធ | នាយរងការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក<br>នៃការិយាល័យចរាចរណ៍ផ្លូវគោករាជធានីភ្នំពេញ | សមាជិក |
| ៧.លោកស្រី បុប្ផា ផានី | អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន<br>នៃមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ | សមាជិកា |
| ៨.លោក កាំង ម៉ូនីកា | ប្រធានផ្នែកអភិវឌ្ឍន៍ធុរកិច្ច<br>នៃសមាគមនិយោជករោងចក្រកាត់ដេរនៅកម្ពុជា | សមាជិក |
| ៩.លោក សោម អូន | ប្រធានសភាសម្ព័ន្ធសហជីពជាតិកម្ពុជា<br>នៃសភាសម្ព័ន្ធសហជីពជាតិកម្ពុជា | សមាជិក |
| ១០.លោក គង់ អាទិត្យ | អនុប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា<br>នៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា | សមាជិក |
| ១១.លោកស្រី ប៉ែន សក្កូនី | ប្រធានគម្រោងអប់រំ និងផ្សព្វផ្សាយ<br>នៃអង្គការ HANDICAP International | សមាជិកា |
| ១២.លោក ជាវ ប៊ុនរិទ្ធ | ប្រធានការិយាល័យគោលនយោបាយ<br>នៃបេឡាជាតិរបបសន្តិសុខសង្គម | សមាជិក |

**ប្រការ ២.-** ប្រធាន អនុប្រធាន សមាជិក ដូចមានចែងក្នុងប្រការ១ និងនាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៤

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
- ក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គម
- ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស
- សាមីអង្គភាព "ដើម្បីជូនជ្រាប"
- ដូចប្រការ២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

## អក្សរកាត់

- **ប.ស.ស** បេឡាជាតិរបបសន្តិសុខសង្គម
- **ស.ផ.ក** ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត
- **NSSF** NATIONAL SOCIAL SECURITY FUND
- **RCVIS** ROAD CRASH AND VICTIM INFORMATION SYSTEM
- **WHO** WORLD HEALTH ORGANIZATION

# ប្រវត្តិរូប និងបទពិសោធន៍ការងាររបស់ក្រុមការងារ ស.ផ.ក



លោក អ៊ុក សមវិទ្យា

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- នាយកបេឡាជាតិរបបសន្តិសុខសង្គម និង ជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត
- បទពិសោធន៍ការងារជាង៧ឆ្នាំ ក្នុងនាយកដ្ឋានបៀវត្សពលកម្ម នៃក្រសួងផែនការ និងបទពិសោធន៍២០ឆ្នាំ ជាប្រធាននាយកដ្ឋាន និងជានាយកបេឡាជាតិរបបសន្តិសុខសង្គមរហូតមកដល់បច្ចុប្បន្ន
- សញ្ញាបត្រ Bacc II នៅឆ្នាំ ១៩៨០, សញ្ញាបត្រវិស្វករ នៅឆ្នាំ១៩៨៦ នៅវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាពសូវៀត និងចុងក្រោយលោកទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ក្នុងឆ្នាំ២០០៧ នៅសាកលវិទ្យាល័យឯកទេសនៃកម្ពុជា
- គ្រឿងឥស្សរយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍។



លោក ព្រាប ច័ន្ទវិបុល

- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក អគ្គលេខាធិការរងគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងជាអនុប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត
- បទពិសោធន៍ការងារ នៅក្នុងក្រសួងសាធារណការ និងដឹកជញ្ជូនបានចំនួនជាង២៦ឆ្នាំ រហូតមកដល់បច្ចុប្បន្ន
- សញ្ញាបត្រ Bacc II នៅឆ្នាំ ១៩៨០ និងសញ្ញាបត្រម៉ាស្ទ័រ វិស្វកម្មយានយន្ត នៅ ZWIC KAU ប្រទេសអាល្លឺម៉ង់ ឆ្នាំ ១៩៨៧
- គ្រឿងឥស្សរយសមេដាយការងារ ថ្នាក់មាស ។



ឧត្តមសេនីយ៍ត្រី
លុយ ឈីន

- ក្រសួងមហាផ្ទៃ
- អនុប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងជាអនុប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករ-និយោជិត
- បទពិសោធន៍ការងារជាង ៣០ឆ្នាំផ្នែកចរាចរណ៍ផ្លូវគោក
- គ្រឿងឥស្សរយសមេដាយការងារ ថ្នាក់មាស ។



លោក នាង ភារិទ្ធ

- ក្រសួងសុខាភិបាល
- អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ និងជាអនុប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត
- បទពិសោធន៍ផ្នែកសុខាភិបាល ជាង១០ឆ្នាំ
- សញ្ញាបត្រDoctor ផ្នែកវេជ្ជសាស្ត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ
- គ្រឿងឥស្សរយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់សេនា ។



វរសេនីយ៍ត្រី
ម៉ក់ ណារិទ្ធ

- ក្រសួងមហាផ្ទៃ
- នាយរងការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក រាជធានីភ្នំពេញ និងជាសមាជិកក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករ-និយោជិត
- បទពិសោធន៍ជាង១០ឆ្នាំ នៅការិយាល័យនគរបាលចរាចរណ៍ផ្លូវគោករាជធានីភ្នំពេញ
- សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រ
- គ្រឿងឥស្សរយសការងារ រាជរដ្ឋាភិបាលកម្ពុជា ។



លោកស្រី បុប្ផា ផានី

- ក្រសួងសាធារណការ និងដឹកជញ្ជូន
- អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ និងជាសមាជិកក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត
- បទពិសោធន៍ការងារជាង២០ឆ្នាំ
- សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែករដ្ឋបាលសាធារណៈ និងផ្នែកគាំពារទារកនៅប្រទេសវៀតណាម
- គ្រឿងឥស្សរយសការងារ ថ្នាក់ធិបឌិន្ទ។



លោក ហុក ហួលីម

- ក្រសួងមហាផ្ទៃ
- នាយកទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្សសាលារាជធានីភ្នំពេញ និងជាសមាជិកក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត
- បទពិសោធន៍ការងារជាង ២០ឆ្នាំ
- សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រនយោបាយ
- គ្រឿងឥស្សរយស មេដាយការងារ ថ្នាក់សេនា។



លោក ជាវ ប៊ុនរិទ្ធ

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ប្រធានការិយាល័យគោលនយោបាយ នៃបេឡាជាតិរបបសន្តិសុខសង្គម និងជាសមាជិកក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត
- បទពិសោធន៍ការងារជាង ១០ឆ្នាំ
- សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រនិងវិទ្យាសាស្ត្រនយោបាយ
- គ្រឿងឥស្សរយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍។



- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- អគ្គលេខាធិការរងនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងជាសមាជិកក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត
- បទពិសោធន៍ការងារជាង១០ឆ្នាំ
- សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ។

**លោក កាំង មុនីកា**



- សភាសម្ព័ន្ធសហជីពជាតិកម្ពុជា
- ប្រធានសភាសម្ព័ន្ធសហជីពជាតិកម្ពុជា និងជាសមាជិកក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត
- បទពិសោធន៍ការងារជាង ១០ឆ្នាំ
- សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ
- គ្រឿងឥស្សរិយសមុនីសារាភ័ណ្ឌ ថ្នាក់ធិបឌិន្ទ ។

**លោក សោម អូន**



- សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា
- អនុប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា និងជាសមាជិកក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត
- បទពិសោធន៍ការងារជាង ១០ឆ្នាំ
- សញ្ញាបត្របរិញ្ញាបត្រផ្នែកព័ត៌មានវិទ្យា
- ពានរង្វាន់ផ្នែកការងារសហជីពអន្តរជាតិ NORWAY INDUSTRY ENERGY ។

**លោក គង់ អាទិត្យ**



**លោកស្រី ប៉ែន សក្ខនី**

- អង្គការជនពិការអន្តរជាតិ
- អនុប្រធានកម្មវិធីសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៃអង្គការជនពិការអន្តរជាតិ និងជាសមាជិកក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត
- បទពិសោធន៍ការងារជាង ៩ឆ្នាំ
- សញ្ញាបត្របរិញ្ញាបត្រផ្នែកអប់រំកាសាអង់គ្លេស នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**បេឡាជាតិរបបសន្តិសុខសង្គម**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារសម្រេចបានឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្ត របស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) បានចាប់ផ្តើមដំណើរការមកដល់ឆ្នាំ២០១៤នេះបានរយៈពេល ២ ឆ្នាំមកហើយ ដែលជាសេនាធិការផ្ទាល់របស់បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានតួនាទីក្នុងការកសាងផែនការសកម្មភាពសំដៅទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកដែលអាចកើតមានក្នុងពេលកម្មករនិយោជិតធ្វើដំណើរ ធ្វើការសិក្សាស្រាវជ្រាវប្រមូលទិន្នន័យ វិភាគរកមូលហេតុចម្បងៗ ដែលនាំឲ្យកើតមានគ្រោះថ្នាក់ចរាចរណ៍ក្នុងពេលធ្វើដំណើររបស់កម្មករនិយោជិត និងស្រង់ស្ថិតិមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និងអ្នកបើកបរតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន នៅទូទាំងប្រទេស។

បច្ចុប្បន្ននេះដែរ គ្រោះថ្នាក់ចរាចរណ៍នៅតែបន្តកើតមានឡើងបណ្តាលឲ្យមានមនុស្ស ស្លាប់ របួស និងពិការ ព្រមទាំងបានបន្សល់ទុកនូវសោកនាដកម្មដ៏រន្ធត់ ដែលផលប៉ះពាល់ទាំងនោះបានក្លាយជាបញ្ហាប្រឈមដ៏គួរឲ្យព្រួយបារម្ភ នៅក្នុងសង្គមកម្ពុជា។ ក្រៅពីបង្កឲ្យមានផលប៉ះពាល់ដោយផ្ទាល់ដល់ប្រជាជន មានជាអាទ៍ការនិរាសព្រាត់ប្រាស់កូនចៅ បងប្អូន ឪពុក ម្តាយ មិត្តភក្តិ គ្រោះថ្នាក់ចរាចរណ៍ក៏បានបណ្តាលឲ្យមាន ការខាតបង់ប្រាក់កាស សេដ្ឋកិច្ចគ្រួសារ និងខាតបង់សេដ្ឋកិច្ចជាតិ អស់រាប់រយលានដុល្លារក្នុងមួយឆ្នាំៗ។ បើយោងតាមទិន្នន័យ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ឆ្នាំ២០១៤ ចំនួនគ្រោះថ្នាក់ការងារ (គ្រោះថ្នាក់ពេលធ្វើដំណើរពីផ្ទះទៅកន្លែងធ្វើការ និងពីកន្លែងធ្វើការត្រឡប់ទៅផ្ទះវិញ) កើតមានឡើងចំពោះកម្មករនិយោជិតមានចំនួន ៣.៨០០ ករណី ដែលបណ្តាលឲ្យកម្មករនិយោជិតទទួលរងគ្រោះថ្នាក់សរុបចំនួន

៤.៧៣៧ នាក់ បើប្រៀបធៀបជាមួយឆ្នាំ ២០១៣ ក្នុងនោះចំនួនគ្រោះថ្នាក់មានការថយចុះចំនួន ០,៩៤%, ជនរងគ្រោះសរុបមានការកើនឡើង០,៧២% ស្លាប់មានការកើនឡើង៨,៩៤% របួសធ្ងន់មានការកើនឡើង ៨,២៣% និងរបួសស្រាលមានការថយចុះចំនួន០,៨២% (**គិតជាមធ្យមមានកម្មករនិយោជិតស្លាប់ចំនួន ៦នាក់ របួសធ្ងន់ចំនួន ៦៥នាក់ និងរបួសស្រាលចំនួន៣២២នាក់ ក្នុងមួយខែ**) ស្របពេលដែលសមាជិក ប.ស.ស មានការកើនឡើងចំនួន៤១៩.៧៦៥នាក់ ស្មើនឹង៦៧,៩៤%។

# ១.-ស្ថានភាពចរាចរណ៍ក្នុងប្រទេសកម្ពុជា

## ១-១-ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ឆ្នាំ ២០១៤



យោងតាមទិន្នន័យរបស់នគរបាលចរាចរណ៍ផ្លូវគោក នៅឆ្នាំ២០១៤ (ចាប់ពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ ដល់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤) មានគ្រោះថ្នាក់ចរាចរណ៍ចំនួន **៤.៨៤០ករណី** ជនរងគ្រោះសរុបចំនួន **១០.២០៥នាក់** ។ ក្នុងចំណោមជនរងគ្រោះទាំងអស់ មានអ្នកស្លាប់ចំនួន ២.១៤៨ នាក់ របួសធ្ងន់ចំនួន ៤.៦៥៤ នាក់ (គិតជាមធ្យមភាគស្លាប់ច្រើនជាង ៥ នាក់ និងរបួសធ្ងន់ ១៣ នាក់ក្នុងមួយថ្ងៃ) និងរបួសស្រាលចំនួន ៣.៤០៣ នាក់ ។ ចំនួនករណីគ្រោះថ្នាក់មានការកើនឡើងចំនួន ៥១៨ នាក់ ស្មើនឹង ១២% ចំនួនអ្នកស្លាប់មានការកើនឡើងចំនួន ២៤៧ នាក់ ស្មើនឹង ១៣% របួសធ្ងន់កើនឡើងចំនួន ៤៤៩ នាក់ ស្មើ១១% និងរបួសស្រាលក៏មានការកើនឡើងដែរគឺចំនួន ៤០០ នាក់ ស្មើនឹង១៣% បើប្រៀបធៀបជាមួយឆ្នាំ២០១៣។

| ល.រ | មុខសញ្ញា | ឯកត្តា | ប្រចាំឆ្នាំ២០១៣ | ប្រចាំឆ្នាំ២០១៤ | កើនឡើង ឬ ថយចុះ | គិតជាភាគរយ |
|---|---|---|---|---|---|---|
| ១ | ចំនួនគ្រោះថ្នាក់ | លើក | ៤.៣២២ | ៤.៨៤០ | ៥១៨ | ១២% |
| ២ | ចំនួនអ្នកស្លាប់ | នាក់ | ១.៩០១ | ២.១៤៨ | ២៤៧ | ១៣% |
| ៣ | ចំនួនអ្នករបួសធ្ងន់ | នាក់ | ៤.២០៥ | ៤.៦៥៤ | ៤៤៩ | ១១% |
| ៤ | ចំនួនអ្នករបួសស្រាល | នាក់ | ៣.០០៣ | ៣.៤០៣ | ៤០០ | ១៣% |
| ៥ | ចំនួនអ្នករងគ្រោះសរុប | នាក់ | **៩.១០៩** | **១០.២០៥** | **១.០៩៦** | **១២%** |






## ១-២-មូលហេតុគ្រោះថ្នាក់ចរាចរណ៍ឆ្នាំ២០១៤



តាមប្រភពទិន្នន័យរបស់នគរបាលចរាចរណ៍ផ្លូវគោក នៅឆ្នាំ២០១៤ (ចាប់ពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ ដល់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤) មានគ្រោះថ្នាក់ចរាចរណ៍ចំនួន **៤.៨៤០ ករណី** ជនរងគ្រោះសរុបចំនួន **១០.២០៥ នាក់** ក្នុងនោះមូលហេតុសំខាន់ៗរួមមាន: ល្មើសល្បឿនចំនួន ២.១១៨ លើក ស្មើនឹង៤៤%, ស្រវឹងចំនួន ៦១៨ លើក ស្មើនឹង១៣%, មិនគោរពសិទ្ធិអាទិភាពចំនួន ៥៩៥ ករណី ស្មើនឹង១២%, ប្រជែងគ្រោះថ្នាក់មានចំនួន ៥១២ ករណី ស្មើនឹង១១%, មិនប្រកាន់ស្តាំចំនួន ៣១៨ ករណី ស្មើនឹង៧%, បត់ឆ្វេង ឬស្តាំមិនប្រយ័ត្នចំនួន ៣២១ ករណី ស្មើនឹង៧%, និងគ្រោះថ្នាក់ដោយមូលហេតុផ្សេងៗ មានចំនួន ២៥៨ ករណី ស្មើនឹង៦% ។

| ល.រ | មូលហេតុ | ប្រចាំ ឆ្នាំ២០១៣ | ប្រចាំ ឆ្នាំ២០១៤ | កើនឡើង ឬ ថយចុះ | គិតជា ភាគរយ |
|---|---|---|---|---|---|
| ១ | ល្មើសល្បឿន | ១.៩៧៧ | ២.១១៨ | ១៤១ | ៧% |
| ២ | ស្រវឹង | ៥៤៣ | ៦១៨ | ៧៥ | ១៤% |
| ៣ | មិនគោរពសិទ្ធិអាទិភាព | ៥៨៦ | ៥៩៥ | ៩ | ១% |
| ៤ | ប្រជែងដោយគ្រោះថ្នាក់ | ៤១១ | ៥១២ | ១០១ | ២៤% |
| ៥ | មិនប្រកាន់ស្តាំ | ២៦៧ | ៣១៨ | ៥១ | ១៩% |
| ៦ | បត់ឆ្វេងឬស្តាំមិនប្រយ័ត្ន | ២២១ | ៣២១ | ១០០ | ៤៥% |
| ៧ | ផ្សេងៗ | ៣១៧ | ២៥៨ | -៤១ | -១២% |






## ២.-គ្រោះថ្នាក់ចរាចរណ៍កម្មករនិយោជិត (គ្រោះថ្នាក់ការងារ) ឆ្នាំ២០១៤

### ២-១-ស្ថានភាពគ្រោះថ្នាក់



យោងតាមរបាយការណ៍បូកសរុបបឋមរបស់ បេឡាជាតិរបបសន្តិសុខសង្គម បានបង្ហាញថាក្នុងឆ្នាំ២០១៤នេះ (ចាប់ពីខែធ្នូ ឆ្នាំ២០១៣ រហូតដល់ខែវិច្ឆិកា ឆ្នាំ ២០១៤) មានគ្រោះថ្នាក់ចរាចរណ៍ (គ្រោះថ្នាក់ពេលធ្វើដំណើរ) សរុបចំនួន ៣.៨០០ ករណី ដែលបណ្តាលឲ្យកម្មករ-និយោជិតទទួលរងគ្រោះថ្នាក់សរុបចំនួន ៤.៧៣៧ នាក់។ ក្នុងនោះបង្កឲ្យមានកម្មករនិយោជិតស្លាប់ចំនួន ៧៣ នាក់ របួសធ្ងន់ចំនួន ៧៨៩ នាក់និង របួសស្រាលចំនួន៣.៨៧៥ នាក់ (ក្នុងនោះដែរគិតជាមធ្យមមានកម្មករនិយោជិតស្លាប់ចំនួន ៦ នាក់ និង របួសធ្ងន់ចំនួនលើសពី ៦៥ នាក់ និងរបួសស្រាលលើសពី ៣២២ នាក់ ក្នុងមួយខែ)។ បើប្រៀបធៀបឆ្នាំ ២០១៣ ជាមួយនឹងឆ្នាំ២០១៤ បានបង្ហាញថាចំនួនគ្រោះថ្នាក់មានការថយចុះចំនួន ៣៦ ករណី, ជនរងគ្រោះសរុបមានការកើនឡើងចំនួន ៣៤ នាក់ ស្លាប់មានការកើនឡើងចំនួន ៦ នាក់ របួសធ្ងន់មានការកើនឡើងចំនួន ៦០ នាក់ និងរបួសស្រាលមានការថយចុះចំនួន ៣២ នាក់។ ទន្ទឹមនឹងការកើនឡើងនូវចំនួនជនរងគ្រោះសរុប អ្នកស្លាប់ និងអ្នករបួសធ្ងន់ ក្នុងនោះដែរ បេឡាជាតិរបបសន្តិសុខសង្គម ក៏មានការកើនឡើងនូវចំនួនសមាជិករបស់ខ្លួនសរុបចំនួន ៤១៩.៧៦៥ នាក់ផងដែរ។

| បរិយាយ | ប្រចាំឆ្នាំ២០១៣ | ប្រចាំឆ្នាំ២០១៤ | កើនឡើង ឬថយចុះ | គិតជាភាគរយ |
|---|---|---|---|---|
| សមាជិកសរុប | ៦១៧.៨១៤ | ១.០៣៧.៥៧៩ | ៤១៩.៧៦៥ | ៦៧,៩៤% |
| ករណី | ៣.៨៣៦ | ៣.៨០០ | -៣៦ | -០,៩៤% |
| ចំនួនអ្នកគ្រោះថ្នាក់សរុប | ៤.៧០៣ | ៤.៧៣៧ | ៣៤ | ០,៧២% |
| ស្លាប់ | ៦៧ | ៧៣ | ៦ | ៨,៩៥% |
| ធ្ងន់ | ៧២៩ | ៧៨៩ | ៦០ | ៨,២៣% |
| ស្រាល | ៣.៩០៧ | ៣.៨៧៥ | -៣២ | -០,៨២% |

ប្រភព:របាយការណ៍បូកសរុបក្រុមការងារស.ផ.ក ឆ្នាំ២០១៣ និងរបាយការណ៍បូកសរុបបឋមប.ស.ស ឆ្នាំ២០១៤


តារាងប្រៀបធៀបចំនួនករណីគ្រោះថ្នាក់ ជនរងគ្រោះសរុប ជនរងគ្រោះតាមប្រភេទ
៥០០០
៤៥០០
៤០០០
៣៥០០
៣០០០
២៥០០
២០០០
១៥០០
១០០០
៥០០
០
៣៨៣៦
៣៨០០
៤៧០៣
៤៧៣៧
៦៧
៧៣
៧២៩
៧៨៩
៣៩០៧
៣៨៧៥
ករណី
ចំនួនអ្នករងគ្រោះថ្នាក់សរុប
ស្លាប់
ធ្ងន់
ស្រាល
ឆ្នាំ ២០១៣
ឆ្នាំ ២០១៤


តារាងប្រៀបធៀបចំនួនគ្រោះថ្នាក់សរុបជាមួយសមាជិកសរុប
ឆ្នាំ២០១៣ និងឆ្នាំ២០១៤
១២០០០០០
១០០០០០០
៨០០០០០
៦០០០០០
៤០០០០០
២០០០០០
០
១០៣៧៥៧៩
៦១៧៨១៤
៤៧០៣
៤៧៣៧
០.៧៦
០.៤៦
សមាជិកសរុប
គ្រោះថ្នាក់សរុប
គិតជាភាគរយ
ឆ្នាំ ២០១៣
ឆ្នាំ ២០១៤


គិតជានាក់ក្នុងមួយខែ
៣៥០
៣០០
២៥០
២០០
១៥០
១០០
៥០
០
៥
៦
៦០
៦៥
៣២៥
៣២២
ស្លាប់
របួសធ្ងន់
របួសស្រាល
ឆ្នាំ ២០១៣
ឆ្នាំ ២០១៤

## ២-២-មូលហេតុគ្រោះថ្នាក់




យោងតាមទិន្នន័យរបស់បេឡាជាតិរបបសន្តិសុខសង្គម គ្រោះថ្នាក់ចរាចរណ៍ (គ្រោះថ្នាក់ពេលធ្វើដំណើរ) ត្រូវបានបែងចែកជា ៤ ប្រភេទ ដាច់ដោយឡែកពីគ្នាទៅតាមមធ្យោបាយធ្វើដំណើររបស់កម្មករនិយោជិត ក្នុងនោះរួមមាន តាមរថយន្ត ម៉ូតូ រ៉ឺម៉ក និងកង់ព្រមទាំងមធ្យោបាយផ្សេងៗ។ យោងតាមទិន្នន័យគ្រោះថ្នាក់ឆ្នាំ ២០១៤ នេះ បានបង្ហាញផងដែរថាក្នុងចំណោមគ្រោះថ្នាក់ចំនួន ៣.៨០០ ករណី ក្នុងនោះមូលហេតុចម្បងបណ្តាលឲ្យគ្រោះថ្នាក់គឺៈ អ្នកប្រើប្រាស់ម៉ូតូមានចំនួន ២.៦៦៩ ករណី ស្មើ៧០%, រថយន្តចំនួន ៣៤៨ ករណី ស្មើ៩%, រ៉ឺម៉កចំនួន ៥២ ករណីស្មើ១% និងដោយកង់ព្រមទាំងមធ្យោបាយផ្សេងៗមានចំនួន ៧៣១ ករណី នឹង១៩% នៃករណីគ្រោះថ្នាក់សរុប។

| ចំនួនគ្រោះថ្នាក់ចរាចរណ៍ឆ្នាំ២០១៤ | | |
|---|---|---|
| **បរិយាយ** | **ចំនួន (ករណី)** | **ភាគរយ** |
| ម៉ូតូ | ២.៦៦៩ | ៧០,២៤% |
| រថយន្ត | ៣៤៨ | ០៩,១៦% |
| រ៉ឺម៉ក | ៥២ | ០១,៤០% |
| កង់ព្រមទាំងមធ្យោបាយផ្សេងៗ | ៧៣១ | ១៩,២៣% |
| **សរុប** | **៣.៨០០** | **១០០%** |






| ចំនួនជនរងគ្រោះតាមប្រភេទ និងតាមមធ្យោបាយធ្វើដំណើរទាំង៤ | | | | | |
|---|---|---|---|---|---|
| បរិយាយ | ម៉ូតូ | រថយន្ត | រ៉ឺម៉ក | កង់ព្រមទាំងមធ្យោបាយផ្សេងៗ | សរុប |
| ករណី | ២.៦៦៩ | ៣៤៨ | ៥២ | ៧៣១ | ៣.៨០០ |
| ចំនួនជនរងគ្រោះ | ៣.០៦៧ | ៧៦២ | ៩១ | ៨១៧ | **៤.៧៣៧** |
| ស្លាប់ | ៦០ | ៧ | ០ | ៦ | ៧៣ |
| របួសធ្ងន់ | ៥៤២ | ១៣៣ | ១៥ | ៩៩ | ៧៨៩ |
| ស្រាល | ២.៤៦៥ | ៦៦២ | ៧៦ | ៦៧២ | ៣.៨៧៥ |








សកម្មភាពមន្ត្រី បុគ្គលិក ប.ស.ស ចុះសម្របសម្រួលករណីគ្រោះថ្នាក់ចរាចរណ៍ និងបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ

## ៣.-លទ្ធផលការងារសម្រេចបាន

### ៣-១-ប្រជុំវិសាមញ្ញ





ក្រុមការងារ ស.ផ.ក នៃ ប.ស.ស បានធ្វើការប្រជុំវិសាមញ្ញបានចំនួន ៥ លើកដែលសម្រេចបានជាលទ្ធផលការងារមួយចំនួនមានដូចខាងក្រោមៈ

- ផែនការសម្រាប់ធ្វើការចុះអនុវត្តការងារសម្រាប់ឆ្នាំ២០១៤
- កែសម្រួលខ្លឹមសារមេរៀនសម្រាប់ប្រជុំចុះផ្សព្វផ្សាយអប់រំ សម្រាប់ឆ្នាំ២០១៤
- របាយការណ៍បូកសរុបឆ្នាំ២០១៣ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៤
- ប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៣ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៤
- ផលិតវីដេអូខ្លី ដែលមានខ្លឹមសារស្តីពីសារៈសំខាន់នៃប័ណ្ណបើកបរ
- ផែនការសកម្មភាពការងារឆ្នាំ២០១៥
- បានទទួលគោលការណ៍ឯកភាពពីអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ស្តីពីការផ្តល់កិច្ចសហការជាមួយស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត
- បានទទួលគោលការណ៍ឯកភាពពីក្រសួងសាធារណការ និងដឹកជញ្ជូន ស្តីពីស្នើសុំនីតិវិធីពិសេសសម្រាប់ជួយសម្រួលដល់អ្នកបើកបរដឹកកម្មករក្នុងការប្រឡងយកប័ណ្ណបើកបរ និងផ្តល់ប័ណ្ណបើកបរ
- កសាងសម្ភារឧបទ្ទេសសម្រាប់ផ្សព្វផ្សាយអប់រំ រួមមានៈ
  - ផ្ទាំងកម្មវិធីប្រជុំផ្សព្វផ្សាយ (Backdrop) និងពាក្យស្លោកអប់រំ (បដាពាក្យស្លោក)
  - ច្បាប់ចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជា
  - កម្រងឯកសារយល់ដឹងស្តីពីសុវត្ថិភាពចរាចរណ៍
  - ខិត្តប័ណ្ណផ្សព្វផ្សាយអប់រំ និងមេរៀនសម្រាប់ផ្សព្វផ្សាយអប់រំ
  - សារអប់រំបោះពុម្ពលើអាវយឺត និងមួក (ថ្ងៃនេះ ថ្ងៃស្អែកកុំឲ្យមានគ្រោះថ្នាក់ចរាចរណ៍)
  - វីដេអូអប់រំខ្លីៗស្តីពីសារៈសំខាន់នៃប័ណ្ណបើកបរ.........
  - សញ្ញាចរាចរណ៍ សិទ្ធិអាទិភាពត្រង់ផ្លូវប្រសព្វ សញ្ញាកំណត់ល្បឿនក្នុងទីប្រជុំជន សារអប់រំសម្រាប់បិទយានយន្ត និងវីដេអូអប់រំខ្លីៗ( ស្តុត)




*បដាពាក្យស្លោកអប់រំ*







*សៀវភៅច្បាប់ចរាចរណ៍ផ្លូវគោក និង កម្រងឯកសារយល់ដឹងពីសុវត្ថិភាពចរាចរណ៍*









**Backdrop**




*មេរៀនសម្រាប់ចុះអប់រំផ្សព្វផ្សាយ*





ខិត្តប័ណ្ណអប់រំស្តីពីច្បាប់ចរាចរណ៍





ខិត្តប័ណ្ណអប់រំស្តីពីបច្ចេកទេសត្រួតពិនិត្យយានយន្ត





ខិត្តប័ណ្ណអប់រំស្តីពីសង្គ្រោះបឋម







*អាវយឺត និងមួក*




Sticker ពាក្យស្លោក





ផ្ទាំងផ្ទាំកសញ្ញាចរាចរណ៍




Sticker កំណត់ល្បឿន






ខិត្តប័ណ្ណអប់រំស្ដីពីការពាក់មួកសុវត្ថិភាព




Sticker បើពិសាគ្រឿងស្រវឹង កុំបើកបរ




Sticker ការពារជីវិតអ្នក កុំបើកបរហួសល្បឿនកំណត់








*វីដេអូអប់រំខ្លីៗស្តីពីសារៈសំខាន់នៃប័ណ្ណបើកបរ*



## ៣-២-ផ្សព្វផ្សាយអប់រំដល់អ្នកបើកបរដឹកកម្មករនិយោជិត

### ៣-២-១-ផ្សព្វផ្សាយអប់រំឆ្នាំ២០១៣

ក្រុមការងារស.ផ.ក បានប្រជុំផ្សព្វផ្សាយអប់រំស្តីពី សុវត្ថិភាពចរាចរណ៍ផ្លូវគោកលើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត ដោយផ្តោតទៅលើច្បាប់ចរាចរណ៍ផ្លូវគោក ការត្រួតពិនិត្យយានយន្តប្រចាំថ្ងៃ និងការសង្គ្រោះបឋម បានចំនួន ២៤ លើក ស្មើនឹង ១៧២ រោងចក្រ ដែលមានទីតាំងស្ថិតនៅ រាជធានីភ្នំពេញ និងខេត្តចំនួន ០៩ (ខេត្តកណ្តាល កំពង់ស្ពឺ ព្រះសីហនុ កោះកុង កំពង់ឆ្នាំង កំពង់ចាម ស្វាយរៀង តាកែវ និងខេត្តព្រៃវែង) ក្នុងនោះមានការអញ្ជើញចូលរួម សរុប **ចំនួន ៤.៧៤៧ នាក់** ( អ្នកបើកបរយានយន្តដឹកកម្មករចំនួន១.៨៦៧ នាក់ និងកម្មករនិយោជិតចំនួន ២.៨៨០ នាក់) ដូចមានលម្អិតទីតាំង និងកាលបរិច្ឆេទខាងក្រោម៖

១- ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣ នៅតំបន់សេដ្ឋកិច្ចពិសេសមេនហាតថេនខេត្តស្វាយរៀង
មានទីតាំងស្ថិតនៅឃុំបាវិត ស្រុកចន្រ្ទា ខេត្តស្វាយរៀង

២- ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣ នៅរោងចក្រ Cambo Handsome Ltd
មានទីតាំងស្ថិតនៅសង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

៣- ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៣ នៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ
មានទីតាំងស្ថិតនៅសង្កាត់ភ្លើងឆេះរទេះ ដណ្ឌដង្កោ រាជធានីភ្នំពេញ

៤- ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣ នៅរោងចក្រ HUEY CHUEN (CAMBODIA) CORP., LTD
មានទីតាំងស្ថិតនៅសង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

៥- ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៣ នៅរោងចក្រ TAK FOOK (CAMBODIA) GARMENT LTD.
មានទីតាំងស្ថិតនៅឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

៦- ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៣ នៅតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ
មានទីតាំងស្ថិតនៅ ឃុំបិតត្រាង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

៧- ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៣ នៅរោងចក្រ TOP SUMMIT GARMENT INC.
មានទីតាំងស្ថិតនៅសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ

៨- ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ នៅរោងចក្រ T Y FASHION (CAMBODIA) CO., LTD
មានទីតាំងស្ថិតនៅឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល

៩- ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ នៅរោងចក្រ M & V INTERNATIONAL MANUFACTURING LTD.
មានទីតាំងស្ថិតនៅឃុំកំពង់ឆ្នាំង ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

១០-ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៣ នៅរោងចក្រ QUINT MAJOR INDUSTRIAL CO., LTD.
មានទីតាំងស្ថិតនៅស្រុកអង្គស្នួល ខេត្តកណ្តាល

១១-ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ នៅរោងចក្រ TAI YAR GARMENT INDUSTRY CO., LTD.
មានទីតាំងស្ថិតនៅស្រុកពញាឮ ខេត្តកណ្តាល

១២- ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅក្រុមហ៊ុន 7NG GROUP CO., Ltd
មានទីតាំងស្ថិតនៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

១៣- ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅក្រុមហ៊ុន 7NG GROUP CO., Ltd
មានទីតាំងស្ថិតនៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

១៤- ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅរោងចក្រ WING STAR SHOES CO., LTD
មានទីតាំងស្ថិតនៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ

១៥- ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅរោងចក្រ MEDTECS ( CAMBODIA ) CORP. LIMITED
មានទីតាំងស្ថិតនៅស្រុកកំពង់សៀម ខេត្តកំពង់ចាម

១៦- ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅសួនឧស្សាហកម្មវឌ្ឍនៈ២
មានទីតាំងស្ថិតនៅសង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ

១៧- ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅរោងចក្រ COMPLETE HONOUR FOOTWEAR INDUSTRIAL ( CAMBODIA ) CO., LTD.
មានទីតាំងស្ថិតនៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ

១៨- ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅរោងចក្រ SIXPLUS INDUSTRY CO., LTD.
មានទីតាំងស្ថិតនៅស្រុកមុខកំពូល ខេត្តកណ្តាល

១៩- ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៣ នៅរោងចក្រ FULL FORTUNE KNITTING LTD
មានទីតាំងស្ថិតនៅស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង

២០- ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៣ នៅរោងចក្រ YTC CORPORATION
មានទីតាំងស្ថិតនៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

២១- ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៣ នៅរោងចក្រ GENERATION INTERNATIONAL CO., LTD.
មានទីតាំងស្ថិតនៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

២២- ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣ នៅតំបន់សេដ្ឋកិច្ចពិសេសខេត្តកោះកុង
មានទីតាំងស្ថិតនៅស្រុកមណ្ឌលសីមា ខេត្តកោះកុង

២៣- ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ នៅរោងចក្រ Asia Dragon ( garment ) co.,ltd
មានទីតាំងស្ថិតនៅស្រុកបាទី ខេត្តតាកែវ

២៤- ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣ នៅរោងចក្រ R SAMBADH TRADING ( KAMPUCHEA ) CO., LTD.
មានទីតាំងស្ថិតនៅស្រុកព្រៃវែង ខេត្តព្រៃវែង

| តារាងប្រជុំផ្សព្វផ្សាយអប់រំតាមបណ្តារាជធានី/ខេត្ត ឆ្នាំ២០១៣ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| បរិយាយ | រាជធានីភ្នំពេញ | កណ្តាល | កំពង់ស្ពឺ | ព្រៃវែង | តាកែវ | ស្វាយរៀង | កំពង់ចាម | កំពង់ឆ្នាំង | កោះកុង | ព្រះសីហនុ |
| ចំនួនប្រជុំ | ៥លើក | ៦លើក | ៤លើក | ១លើក | ១លើក | ២លើក | ១លើក | ២លើក | ១លើក | ១លើក |
| ចំនួនរោងចក្រ | ៦០ | ៤៧ | ៥ | ១ | ១ | ២១ | ១ | ៦ | ៤ | ២៦ |
| ចំនួនអ្នកបើកបរ | ៣៤៦ | ៤៣៩ | ៣២៦ | ២៧ | ៣៤ | ២៩៥ | ៣៧ | ១៨៧ | ៣៤ | ១៩២ |

### ៣-២-២-ផ្សព្វផ្សាយអប់រំឆ្នាំ២០១៤

ក្រុមការងារស.ផ.ក បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំស្តីពី សុវត្ថិភាពចរាចរណ៍ផ្លូវគោក លើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត ដោយផ្អែកទៅលើច្បាប់ចរាចរណ៍ផ្លូវគោក ការត្រួតពិនិត្យយានយន្តប្រចាំថ្ងៃ និងការសង្គ្រោះបឋម បានចំនួន ២២ លើក ស្មើនឹង ១២៣ រោងចក្រ ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ និងខេត្តចំនួន ១១ (ខេត្តកណ្តាល កំពង់ស្ពឺ បន្ទាយមានជ័យ កំពត ពោធិ៍សាត់ ព្រះសីហនុ កោះកុង កំពង់ឆ្នាំង កំពង់ចាម ស្វាយរៀង និងខេត្តតាកែវ) ក្នុងនោះមានការអញ្ជើញចូលរួម សរុប ចំនួន ៤.២៧៥ នាក់ អ្នកបើកបរយានយន្តដឹកកម្មករចំនួន ១.៦០០ នាក់ និងកម្មករនិយោជិតចំនួន ២.៦៧៥ នាក់ ដូចមានលម្អិតទីតាំង និងកាលបរិច្ឆេទខាងក្រោម៖

១- ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ នៅតំបន់សេដ្ឋកិច្ចពិសេស តាយ សេង
មានទីតាំងស្ថិតនៅឃុំបាវិត ស្រុកចន្ទ្រា ខេត្តស្វាយរៀង

២- ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤ នៅរោងចក្រ Best Way Industrial co.,ltd
មានទីតាំងស្ថិតនៅឃុំបាវិត ស្រុកចន្ទ្រា ខេត្តស្វាយរៀង

៣- ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ នៅរោងចក្រ TAIEASY INTERNATIONAL CO., LTD.
មានទីតាំងស្ថិតនៅឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់

៤- ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤ នៅសាលាស្រុកកំពង់ត្រឡាច
មានទីតាំងស្ថិតនៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

៥- ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៤ នៅរោងចក្រ CAMBO KOTOP LTD.
មានទីតាំងស្ថិតនៅសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ

៦- ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤ នៅរោងចក្រ JUHUI FOOTWEAR CO., LTD.
មានទីតាំងស្ថិតនៅឃុំខ្នាជំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម

៧- ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ នៅតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ
មានទីតាំងស្ថិតនៅឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

៨- ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៤ នៅរោងចក្រ KANDATEX KNIT INDUSTRIAL CO., LTD
និងរោងចក្រ DIRECT ROUTE CO., LTD. មានទីតាំងស្ថិតនៅស្រុកទឹកឈូ ខេត្តកំពត

៩- ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ នៅតំបន់សេដ្ឋកិច្ចពិសេសខេត្តកោះកុង
មានទីតាំងស្ថិតនៅក្រុងខេមរភូមិន្ទ ខេត្តកោះកុង

១០-ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ នៅសួនឧស្សាហកម្មវឌ្ឍនៈ ២
មានទីតាំងស្ថិតនៅសង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ

១១-ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ នៅរោងចក្រ M & V INTERNATIONAL MANUFACTURING
មានទីតាំងស្ថិតនៅស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

១២- ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៤ នៅរោងចក្រ tak fook (Cambodia) garment ltd
មានទីតាំងស្ថិតនៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

១៣- ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ នៅក្រុមហ៊ុន 7NG GROUP CO., Ltd
មានទីតាំងស្ថិតនៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

១៤- ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ នៅក្រុមហ៊ុន 7NG GROUP CO., Ltd
មានទីតាំងស្ថិតនៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

១៥- ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៤ នៅរោងចក្រ Wing star shoes co., ltd
មានទីតាំងស្ថិតនៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ

១៦- ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ នៅរោងចក្រ YTC CORPORATION
មានទីតាំងស្ថិតនៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

១៧- ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៤ នៅរោងចក្រ NISHIKU ENTERPRISE CO. LTD.
មានទីតាំងស្ថិតនៅស្រុកបាទី ខេត្តតាកែវ

១៨- ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ នៅរោងចក្រ HI-TECH APPAREL (CAMBODIA)CO., LTD.
និងរោងចក្រ CAMPACK CO., LTD មានទីតាំងស្ថិតនៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ

១៩- ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៤ នៅរោងចក្រ TOP SUMMIT GARMENT INC.
មានទីតាំងស្ថិតនៅសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ

២០- ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៤ នៅរោងចក្រ FU CHUEN ( CAMBODIA ) CORP LTD.
មានទីតាំងស្ថិតនៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

២១- ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៤ នៅរោងចក្រ FULL FORTUNE KNITTING LTD
មានទីតាំងស្ថិតនៅឃុំស្វាយតឿ ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង

២២- ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៤ នៅរោងចក្រ COMPLETE HONOUR FOOTWEAR INDUSTRIAL ( CAMBODIA ) CO., LTD
មានទីតាំងស្ថិតនៅឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

| បរិយាយ | ភ្នំពេញ | កណ្តាល | កំពង់ស្ពឺ | កំពត | តាកែវ | ស្វាយរៀង | កំពង់ចាម | កំពង់ឆ្នាំង | កោះកុង | ព្រះសីហនុ | បន្ទាយមានជ័យ | ពោធិ៍សាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រជុំ | ៤ | ២ | ៣ | ១ | ១ | ៣ | ១ | ៣ | ១ | ១ | ១ | ១ |
| រោងចក្រ | ២៤ | ២០ | ៤ | ៣ | ១ | ២៨ | ១ | ៧ | ៦ | ២៦ | ២ | ១ |
| អ្នកបើកបរ | ៣២៨ | ១៩៥ | ២៣៨ | ៥០ | ៤៥ | ១៩៥ | ៧៤ | ២៧៩ | ៤១ | ៨៥ | ០ | ៧០ |




ពិធីប្រជុំផ្សព្វផ្សាយនៅស្រុកកំពង់ត្រឡាច



ការចូលរួមប្រជុំផ្សព្វផ្សាយអប់រំរបស់អ្នកបើកបរ

## ៣-៣- ប្រៀបធៀបទិន្នន័យអំពីអ្នកបើកបរឆ្នាំ២០១៣ និងឆ្នាំ២០១៤

### ៣-៣-១-ប័ណ្ណបើកបរ

ក្នុងឆ្នាំ២០១៤ ក្នុងចំណោមអ្នកបើកបរចំនួន ១.៦០០ នាក់ ដែលបានចូលរួម ក្នុងនោះអ្នកបើកបរដែលមានប័ណ្ណបើកបរមានចំនួន ៧៨៦ នាក់ ស្មើនឹង ៤៩,១២% និងមិនមានប័ណ្ណបើកបរចំនួន ៨១៤ នាក់ស្មើនឹង ៥០,៨៨% ។ ប្រៀបធៀបជាមួយឆ្នាំ២០១៣ ចំនួនអ្នកបើកបរដែលមានប័ណ្ណបើកបរមានការកើនឡើងចំនួន ៣២៣ នាក់ ស្មើនឹង ៦៩,៧៦% មិនមានប័ណ្ណបើកបរមានការថយចុះចំនួន ៥៩១ នាក់ ស្មើនឹង ៤២,០៦%។

| បរិយាយ | ឆ្នាំ២០១៣ | ឆ្នាំ២០១៤ | | ប្រៀបធៀប | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មានប័ណ្ណបើកបរ | ៤៦៣នាក់ | ៧៨៦នាក់ | ៤៩,១២% | ៣២៣ | ៦៩,៧៦% |
| មិនមានប័ណ្ណបើកបរ | ១.៤០៥នាក់ | ៨១៤នាក់ | ៥០,៨៨% | -៥៩១ | -៤២,០៦% |
| សរុប | ១.៨៦៧នាក់ | ១.៦០០នាក់ | ១០០% | -២៦៧ | -១៤,៣០% |






### ៣-៣-២-ផ្លាកលេខ

យានយន្តដឹកកម្មករដែលមានផ្លាកលេខត្រឹមត្រូវមានចំនួន ១.១៣៣ យានយន្ត និងមិនទាន់មានផ្លាកលេខត្រឹមត្រូវចំនួន ៤៦៧ យានយន្ត។ ប្រៀបធៀបជាមួយឆ្នាំ២០១៣ ចំនួនយានយន្តដែលមានផ្លាកលេខមានការកើនឡើងចំនួន ១១៧ យានយន្ត ស្មើនឹង១១,៥១% និងយានយន្តមិនមានផ្លាកលេខត្រឹមត្រូវមានការថយចុះចំនួន ៣៨៤ យានយន្ត ស្មើនឹង៤៥,១២%។

| បរិយាយ | ឆ្នាំ២០១៣ | ឆ្នាំ២០១៤ | | ប្រៀបធៀប | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| **មានផ្លាកលេខ** | ១.០១៦ | ១.១៣៣ | ៧០,៨១% | ១១៧ | ១១,៥១% |
| **មិនមានផ្លាកលេខ** | ៨៥១ | ៤៦៧ | ២៩,១៨% | -៣៨៤ | -៤៥,១២% |
| **សរុប** | ១.៨៦៧ | ១.៦០០ | ១០០% | ២៦៧ | ១៤,៣០% |






### ៣-៣-៣-តាមប្រភេទយានយន្តនីមួយៗ

ករណីសិក្សាអំពីប្រភេទយានយន្តដឹកកម្មករទាំងប្រាំប្រភេទ ក្នុងនោះសម្រាប់ឆ្នាំ២០១៤ រ៉ឺម៉កនិងកង់បី មានចំនួន ១៨៤ យានយន្ត ស្មើនឹង ១១,៥%, រថយន្តទូរីស (១២កៅអី-១៥កៅអី) ចំនួន ២៨៤ គ្រឿង ស្មើនឹង ១៧,៧៥%, រថយន្ត១តោន-១,៥តោន ចំនួន ៨៨០ គ្រឿង ស្មើនឹង៥៥%, រថយន្ត២តោន-២,៥តោនចំនួន ២២៣ គ្រឿង ស្មើនឹង១៣,៩៤% និងរថយន្ត៣តោនមានចំនួន ២៩ គ្រឿង ស្មើនឹង ១,៨១%។ បើប្រៀបធៀបឆ្នាំ២០១៣ និងឆ្នាំ២០១៤ រ៉ឺម៉ក់និងកង់បី ថយចុះចំនួន ៣៣ យានយន្ត ស្មើនឹង ១៥,២០%, រថយន្តទូរីស (១២កៅអី-១៥កៅអី) ថយចុះចំនួន ១៨៦ គ្រឿង ស្មើនឹង ៣៩,៥៧%, រថយន្ត១តោន-១,៥តោន ថយចុះចំនួន ៥៦ គ្រឿង ស្មើនឹង៥,៩៨%, រថយន្ត២តោន-២,៥តោនកើនឡើងចំនួន ១៣គ្រឿង ស្មើនឹង៦,១៩% និងរថយន្ត៣តោនមានការថយចុះចំនួន ៥ គ្រឿង ស្មើនឹង ១៤,៧០%។







| បរិយាយ | ឆ្នាំ២០១៣ | ឆ្នាំ២០១៤ | | ប្រៀបធៀប | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| រ៉ឺម៉ក និងកង់បី | ២១៧ | ១៨៤ | ១១,៥% | -៣៣ | ១៥,២០% |
| ទូរីស (១២កៅអី-១៥កៅអី) | ៤៧០ | ២៨៤ | ១៧,៧៥% | -១៨៦ | ៣៩,៥៧% |
| ១តោន-១,៥តោន | ៩៣៦ | ៨៨០ | ៥៥% | -៥៦ | ៥,៩៨% |
| ២តោន-២,៥តោន | ២១០ | ២២៣ | ១៣,៩៤% | ១៣ | ៦,១៩% |
| ៣តោន | ៣៤ | ២៩ | ១,៨១% | -៥ | ១៤,៧០% |
| សរុប | ១.៨៦៧ | ១.៦០០ | ១០០% | ២៦៧ | ១៤,៣០% |

### ៣-៣-៤-ស្ថានភាពនៃការធ្វើដំណើររបស់កម្មករនិយោជិត

ក្នុងចំណោមប្រភេទនៃយានយន្តដឹកកម្មករទាំងប្រាំប្រភេទ ត្រូវបែងចែកជាពីរស្ថានភាពរួមមាន ឈរ និងអង្គុយ ក្នុងឆ្នាំ២០១៤ នេះដែរ ស្ថានភាពអង្គុយក្នុងពេលធ្វើដំណើរមានចំនួន ៩៧២ យានយន្ត និងស្ថានភាពឈរក្នុងពេលធ្វើដំណើរមានចំនួន ៦២៨ យានយន្ត។ ប្រៀបធៀបជាមួយឆ្នាំ២០១៣ ស្ថានភាពនៃការធ្វើដំណើរដោយអង្គុយ មានការថយចុះចំនួន ១៧៣ យានយន្ត ស្មើនឹង -១៥,១១% និងស្ថានភាពធ្វើដំណើរដោយឈរ មានការថយចុះចំនួន ៩៤ យានយន្ត ស្មើនឹង -១៣,០១% ។

| បរិយាយ | ឆ្នាំ២០១៣ | ឆ្នាំ២០១៤ | | ប្រៀបធៀប | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| អង្គុយ | ១.១៤៥ | ៩៧២ | ៦០,៧៥% | -១៧៣ | -១៥,១១% |
| ឈរ | ៧២២ | ៦២៨ | ៣៩,២៥% | -៩៤ | -១៣,០២% |
| សរុប | ១.៨៦៧ | ១.៦០០ | ១០០% | ២៦៧ | ១៤,៣០% |

## ៣-៤.សិក្ខាពីអ្នកបើកបរ និងតំណាងរោងចក្រ

### ៣-៤-១-ករណីសិក្សាអំពីអ្នកបើកបរដឹកកម្មករនិយោជិត

ឆ្លងតាមការប្រជុំផ្សព្វផ្សាយក្នុងឆ្នាំ២០១៣ អ្នកបើកបរដឹកជញ្ជូនកម្មករនិយោជិតភាគច្រើនមានចំណាប់អារម្មណ៍ចំពោះការរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ការត្រួតពិនិត្យយានយន្តប្រចាំថ្ងៃ និងការសង្គ្រោះបឋម ដែលមានដូចខាងក្រោមៈ



-តំណាងអ្នកបើកបរនៅរោងចក្រ CAMBO KOTOP LTD ថ្លែងអំណរគុណក្រុមការងារដែលបានរៀបចំកម្មវិធីនេះឡើងព្រោះគាត់គិតថា បានបង្កើនការយល់ដឹងពាក់ព័ន្ធ ច្បាប់ចរាចរណ៍ ការថែទាំយានយន្ត និងការសង្គ្រោះបឋមមុនបញ្ជូនទៅមន្ទីរពេទ្យដល់អ្នកបើកបរដឹកកម្មករនិយោជិតទាំងអស់ ដើម្បីចូលរួមចំណែកទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ដែលកើតឡើង ។ គាត់ក៏បានស្នើសុំឲ្យមានការរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយនេះឲ្យបានញឹកញាប់ និងសូមប្តេជ្ញាថានឹងបន្តផ្សព្វផ្សាយដល់អ្នកដែលមិនបានចូលរួមនៅថ្ងៃនេះឲ្យយល់ដឹងពីសុវត្ថិភាពច្បាប់ចរាចរណ៍ ការថែទាំយានយន្ត និងការសង្គ្រោះបឋម ។

-តំណាងអ្នកបើកបរនៅស្រុកកំពង់ត្រឡាចបានមានមតិលើកឡើងថាការផ្សព្វផ្សាយអប់រំនេះពិតជាល្អណាស់សម្រាប់ជួយដាស់តឿនស្មារតីអ្នកបើកបរឲ្យមានការប្រុងប្រយ័ត្នបន្ថែមលើការដឹកជញ្ជូនកម្មករនិយោជិត ធ្វើឲ្យអ្នកបើកបរមានការខិតខំប្រឹងប្រែងបន្ថែមនូវការសិក្សានិងការវិវត្តន៍នៃច្បាប់ចរាចរណ៍ផ្លូវគោក ជាចុងក្រោយលោកបានស្នើសុំឲ្យមានវគ្គនេះបន្តទៀតមិនថានៅស្រុកកំពង់ត្រឡាច ឬស្រុករាជធានីភ្នំពេញ ឬខេត្តទេ ហើយលោកក៏សូមអំពាវនាវដល់អ្នកបើកបរទាំងអស់គោរពច្បាប់ចរាចរណ៍ ចេះអធ្យាស្រ័យគ្នា កុំបើកបរហួសល្បឿនកំណត់ កុំបើកបរក្រោមឥទ្ធិពលគ្រឿងស្រវឹង និងមានប័ណ្ណបើកបរគ្រប់ៗគ្នា ។



### ៣-៤-២-ករណីសិក្សាអំពីនិយោជក (ម្ចាស់រោងចក្រ)

-តំណាងរោងចក្រ TAIEASY INTERNATIONAL CO., LTD ខេត្តពោធិ៍សាត់ បានមានមតិថា ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត រៀបចំវគ្គបណ្តុះបណ្តាលនេះឡើង ពិតជាមានសារៈសំខាន់ណាស់ដល់បណ្តារោងចក្រ សហគ្រាស គ្រឹះស្ថាននានា ក្នុងការទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ចំពោះកម្មករ-និយោជិត ។ លោកក៏បានលើកឡើងបន្ថែមទៀតថា បើមានគ្រោះថ្នាក់ចរាចរណ៍កើតឡើងមកលើ កម្មករនិយោជិត គឺមានការខាតបង់ដល់សង្វាក់ផលិតកម្មរបស់និយោជក និងរោងចក្រ សហគ្រាស គ្រឹះស្ថាននានាក៏មានកេរ្តិ៍ឈ្មោះមិនល្អទៀតផង ជាពិសេសមិនដែលមានក្រុមការងារណាដែលមកធ្វើការអប់រំ និងបណ្តុះ-បណ្តាលដូចនេះដែរ។






-អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តស្វាយរៀង ប្រចាំតំបន់សេដ្ឋកិច្ចពិសេសខេត្តស្វាយរៀង បានមានមតិលើកឡើងថា នៅតំបន់សេដ្ឋកិច្ចរបស់លោកអ្នកបើកបរភាគច្រើន សុទ្ធតែបានសិក្សានៅសាលារៀនបើកបរ និងមានប័ណ្ណបើកបរទាំងអស់គ្នា បើគ្មានប័ណ្ណបើកបរ តំបន់ក៏បានជម្រុញឲ្យអ្នកបើកបរដឹកកម្មករទៅប្រឡងយកប័ណ្ណបើកបរផងដែរ ។ វគ្គនេះ ពិតជាមានសារៈប្រយោជន៍ ជាពិសេសអ្នកបើកបរដឹកកម្មករនិយោជិត ឲ្យជ្រាបបន្ថែមនូវចំណេះដឹងនៃច្បាប់ចរាចរណ៍ផ្លូវគោក និងអ្នកបើកបរមានការទទួលខុសត្រូវចំពោះគ្រោះថ្នាក់ដែលកើតឡើង ។

## ៣-៥-ផ្សព្វផ្សាយអប់រំដល់ និយោជក នាយក ម្ចាស់ ឬតំណាង សហគ្រាស គ្រឹះស្ថាន



កិច្ចប្រជុំផ្សព្វផ្សាយអប់រំ នៅខេត្តរតនគិរី

ឆ្នាំ២០១៤ ក្រុមការងារ ស.ផ.ក បានចូលរួមសហការផ្សព្វផ្សាយអប់រំស្តីពីច្បាប់ចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ ក្នុងពិធីផ្សព្វផ្សាយអប់រំ ស្តីពីគោលនយោបាយថ្មីៗ និងសេវានៃការផ្តល់តាវកាលិកហានិភ័យការងារជូនកម្មករ និយោជិត របស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៅតាមបណ្តារាជធានី/ខេត្តចំនួន ១៤ (រាជធានីភ្នំពេញ សៀមរាប កំពត កែប ព្រះសីហនុ កំពង់ចាម កំពង់ឆ្នាំង បាត់ដំបង កំពង់ធំ តាកែវ ពោធិ៍សាត់ ក្រចេះ រតនគិរី និងបន្ទាយមានជ័យ) ស្មើនឹង ២៣លើក ដែលក្នុងនោះមានការអញ្ជើញចូលរួមមកពី និយោជក នាយក ម្ចាស់ ឬតំណាង សហគ្រាស គ្រឹះស្ថាន មន្ទីរពេទ្យ ធនាគារ ACLEDA នៅតាមរាជធានី/ខេត្តនីមួយៗ ដូចមានលម្អិតទីតាំង និងកាលបរិច្ឆេទខាងក្រោមៈ



កិច្ចប្រជុំផ្សព្វផ្សាយអប់រំ នៅខេត្តបន្ទាយមានជ័យ

១- ចាប់ពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ នៅសាលប្រជុំ ប.ស.ស មានទីតាំងស្ថិតនៅសង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

២- ចាប់ពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ នៅសាលប្រជុំ ប.ស.ស មានទីតាំងស្ថិតនៅសង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៣- ចាប់ពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ នៅសាលប្រជុំ ប.ស.ស មានទីតាំងស្ថិតនៅសង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៤- ចាប់ពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នៅសាលប្រជុំ ប.ស.ស មានទីតាំងស្ថិតនៅសង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- ចាប់ពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នៅសាលប្រជុំ ប.ស.ស មានទីតាំងស្ថិតនៅសង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៦- ចាប់ពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤ នៅសាលប្រជុំ ប.ស.ស
មានទីតាំងស្ថិតនៅសង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
៧- ចាប់ពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ពេលព្រឹក នៅសាលប្រជុំ ប.ស.ស
មានទីតាំងស្ថិតនៅសង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
៨- ចាប់ពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ពេលរសៀល នៅសាលប្រជុំ ប.ស.ស
មានទីតាំងស្ថិតនៅសង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
៩- ចាប់ពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ ពេលព្រឹកនៅសាលប្រជុំ ប.ស.ស
មានទីតាំងស្ថិតនៅសង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
១០- ចាប់ពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ ពេលរសៀល នៅសាលប្រជុំ ប.ស.ស
មានទីតាំងស្ថិតនៅសង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
១១- ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៤ នៅសណ្ឋាគារ ANGKORLAND HOTEL
មានទីតាំងស្ថិតនៅភូមិតាកុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប
១២- ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៤ នៅសណ្ឋាគារ ANGKORLAND HOTEL
មានទីតាំងស្ថិតនៅភូមិតាកុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប
១៣- ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤ នៅសណ្ឋាគារ កំពត ឱយ៉ាម៉ង
មានទីតាំងស្ថិតនៅសង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត
១៤- ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ នៅសណ្ឋាគារតោមាស
មានទីតាំងស្ថិតនៅសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
១៥- ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤ នៅសណ្ឋាគាររស្មីសុខាញ៉ូវយ៉ក
មានទីតាំងស្ថិតនៅឃុំកំពង់ឆ្នាំង ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
១៦- ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ នៅសណ្ឋាគារភ្នំប្រុស
មានទីតាំងស្ថិតនៅឃុំកំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម
១៧- ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៤ នៅសណ្ឋាគាររស្មីបាត់ដំបង
មានទីតាំងស្ថិតនៅភូមិអូរចា ស្រុកបាត់ដំបង ខេត្តបាត់ដំបង
១៨- ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤ នៅភោជនីយដ្ឋាន ម្លប់ស្វាយធំ
មានទីតាំងស្ថិតនៅឃុំដំរីជាន់ខ្លា ស្រុកស្ទឹងសែន ខេត្តកំពង់ធំ
១៩- ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៤ នៅភោជនីយដ្ឋានសុធារី
មានទីតាំងស្ថិតនៅសង្កាត់រការក្នុង ក្រុងដូនកែវ ខេត្តតាកែវ

២០- ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៤ នៅសណ្ឋាគារហេនសួគ៍ថ្មី

មានទីតាំងស្ថិតនៅឃុំផ្ទះព្រៃ ស្រុកពោធិ៍សាត់ ខេត្តពោធិ៍សាត់

២១- ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ នៅសណ្ឋាគារលីជី

មានទីតាំងស្ថិតនៅ សង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ

២២- ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ នៅសណ្ឋាគារអេសអិន បឹងកំសាន្ត

មានទីតាំងស្ថិតនៅឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនគិរី

២៣- ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅសណ្ឋាគារ លី ហេងឆាយ

មានទីតាំងស្ថិតនៅសង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

## ៤. បញ្ហាប្រឈម

- អ្នកបើកបរដឹកកម្មករនិយោជិតភាគច្រើនមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាន
- នៅមានអ្នកបើកបរដឹកកម្មករនិយោជិត ៤២% គ្មានប័ណ្ណបើកបរ
- អ្នកបើកបរមួយចំនួនវ័យក្មេងអាយុក្រោម២៥ឆ្នាំ
- អ្នកបើកបរមួយចំនួនមានប័ណ្ណបើកបរ មិនត្រូវតាមប្រភេទយាន
- អ្នកបើកបរមួយចំនួនបើកបរក្នុងស្ថានភាពស្រវឹង
- មធ្យោបាយដឹកជញ្ជូនកម្មករ ផ្ទុកលើសចំណុះ
- មធ្យោបាយដឹកជញ្ជូនកម្មករ មួយចំនួនចាស់ទ្រុឌទ្រោម
- រថយន្តពុំមានការត្រួតពិនិត្យតាមលក្ខណៈបច្ចេកទេស
- នៅមានខ្វះស្មារតីក្នុងការត្រួតពិនិត្យយានយន្តប្រចាំថ្ងៃ
- យានយន្តកែច្នៃខុសលក្ខណៈបច្ចេកទេស
- គ្រោះថ្នាក់ដោយអ្នកប្រើប្រាស់ម៉ូតូកើតមានឡើងគួរឲ្យចាប់អារម្មណ៍
- អ្នកបើកបរទោចក្រយានយន្តមួយចំនួនមិនទាន់បានប្រើប្រាស់មួកសុវត្ថិភាពបានត្រឹមត្រូវ
- នៅមានយានយន្តមួយចំនួនគ្មានផ្លាកលេខ និងគ្មានឯកសារគ្រប់គ្រាន់ជាប់តាមខ្លួន។

## ៥. ដំណោះស្រាយ

- សម្របសម្រួលជាមួយរោងចក្រ សហគ្រាស គ្រឹះស្ថាន រៀបចំធ្វើការគ្រប់គ្រងអ្នកបើកបរដឹកកម្មករនិយោជិតដោយផ្ទាល់
- ជម្រុញលើកទឹកចិត្តដល់រោងចក្រ សហគ្រាស គ្រឹះស្ថានណាដែលបានគ្រប់គ្រងអ្នកបើកបរដឹកកម្មករនិយោជិតដោយផ្ទាល់
- ជម្រុញឲ្យអ្នកបើកបរដឹកកម្មករនិយោជិតចូលរៀនបើកបរ និងប្រឡងយកប័ណ្ណបើកបរតាមប្រភេទយាន, យានយន្តមានផ្លាកលេខ វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេស មានទំនួលខុសត្រូវលើមុខរបររបស់ខ្លួន និងធ្វើការតាមដានត្រួតពិនិត្យជាប្រចាំ
- រោងចក្រ សហគ្រាស គ្រឹះស្ថាន ត្រូវបង្កើតកម្មវិធីអប់រំបណ្តុះបណ្តាលបំប៉នសមត្ថភាពផ្នែកច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជាដល់អ្នកបើកបរដឹកកម្មករនិយោជិត
- មានការលើកទឹកចិត្តបន្ថែមចំពោះអ្នកបើកបរល្អ
- បង្កើនការផ្សព្វផ្សាយអប់រំទៅដល់កម្មករនិយោជិត
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធរឹតបន្តឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកជាប្រចាំដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត និងអ្នកប្រើប្រាស់ម៉ូតូ។

## ៦. ទិសដៅអនុវត្តបន្ត

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត បាននឹងកំពុងខិតខំអស់ពីកម្លាំងកាយចិត្ត ដើម្បីរួមចំណែកទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ចំពោះកម្មករនិយោជិត និងមានផែនការសកម្មភាពសម្រាប់ការងាររបស់ខ្លួនដូចតទៅ៖

- បន្តសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ វិភាគរកមូលហេតុចម្បងៗ ស្រង់ស្ថិតិមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និងអ្នកបើកបរ តាមរោងចក្រ សហគ្រាស គ្រឹះស្ថាន ទូទាំងប្រទេស
- បន្តចុះផ្សព្វផ្សាយអប់រំ ណែនាំច្បាប់ និងសុវត្ថិភាពចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរដឹកកម្មករ និងកម្មករនិយោជិតនៅតាមបណ្តាសហគ្រាស គ្រឹះស្ថាននានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត
- បន្តសហការជាមួយអាជ្ញាធរ ភាគីពាក់ព័ន្ធ ក្នុងពេលអនុវត្តនការងារ
- ពង្រឹងកិច្ចសហការ និងសម្របសម្រួលករណីគ្រោះថ្នាក់ចរាចរណ៍ដល់កម្មករនិយោជិត
- ពង្រឹងយន្តការគ្រប់គ្រងរបស់ក្រុមការងារ ស.ផ.ក
- ផលិតវីដេអូអប់រំ(ស្ពត) ស្តីពីការសង្គ្រោះបឋម ក្នុងឆ្នាំ២០១៥
- បើកវគ្គបណ្តុះបណ្តាលសង្គ្រោះបឋម តាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថាន
- សហការជាមួយអធិការដ្ឋាននគរបាល ខណ្ឌ ស្រុក ក្រុង នៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដើម្បីចុះផ្សព្វផ្សាយ និងអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងស្រង់ស្ថិតិយានយន្ត និងអ្នកបើកបរដឹកកម្មករនិយោជិត តាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថាន
- សហការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានី ខេត្ត ដើម្បីបើកវគ្គបណ្តុះបណ្តាល និងប្រឡងយកប័ណ្ណបើកបរ។

## ៧.លទ្ធផលរំពឹងទុក

ឆ្លងតាមការចុះធ្វើការសិក្សាស្រាវជ្រាវកន្លងមក ឆ្នាំ២០១៤ នេះសបញ្ជាក់ឲ្យឃើញថា ឥរិយាបថរបស់អ្នកបើកបរដឹកកម្មករ និងកម្មករនិយោជិតមានការកែប្រែច្រើន រួមមាន៖

- ការចេះត្រួតពិនិត្យយានយន្ត ជាប្រចាំ (កង់, ចង្កូត, ហ្វ្រាំង, ភ្លើង ...)
- ការយល់ដឹងពីច្បាប់ចរាចរណ៍បន្ថែម ពិសេស ការបើកបរក្នុងល្បឿនកំណត់ បើកបរមិនស្ថិតក្រោមឥទ្ធិពលគ្រឿងស្រវឹង បើកបរដោយគោរពសិទ្ធិអាទិភាព មិនដេកក្នុងស្ថានភាពគ្រោះថ្នាក់
- ការយល់ដឹងពីសញ្ញាចរាចរណ៍ផ្លូវគោក
- ការទទួលបានប័ណ្ណបើកបរ ទៅតាមប្រភេទយាន
- ឯកសារសម្រាប់ចរាចរណ៍យានយន្តគ្រប់គ្រាន់
- ការផ្ទុកកម្មករចំនួនសមរម្យ
- ការពាក់មួកសុវត្ថិភាព និងខ្សែក្រវាត់សុវត្ថិភាព បានត្រឹមត្រូវ
- ការចេះវិជ្ជាសង្គ្រោះបឋម សម្រាប់ជួយកម្មករពេលមានគ្រោះថ្នាក់ចរាចរណ៍ ឬសន្លប់។

# ៨. សេចក្តីសន្និដ្ឋាន

អនុវត្តនតាមផែនការសកម្មភាពការងារ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត សម្រេចបានជាលទ្ធផលការងារគួរឲ្យកត់សម្គាល់ លើការសហការជាមួយ អាជ្ញាធរមានសមត្ថកិច្ច រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សួនឧស្សាហកម្ម និងរោងចក្រ សហគ្រាស គ្រឹះស្ថាននានា ជាពិសេសមានការចូលរួមយ៉ាងយកចិត្តទុកដាក់ និងមានការគាំទ្រយ៉ាងខ្លាំងពីសំណាក់ និយោជក អ្នកបើកបរដឹកកម្មករ និងកម្មករនិយោជិត ដើម្បីរៀបចំប្រជុំផ្សព្វផ្សាយអប់រំអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកលើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិតដោយផ្តោតលើច្បាប់ចរាចរណ៍ វិធីសាស្ត្រថៃទាំ និងត្រួតពិនិត្យយានយន្ត ។ សម្រាប់ការអនុវត្តនៅក្នុងឆ្នាំ២០១៤ ក្រុមការងារ ស.ផ.ក បានចុះផ្សព្វផ្សាយអប់រំ និងស្រង់ស្ថិតិ ចំនួន ១២/២៥ រាជធានី/ខេត្ត ស្មើនឹង ២២ លើក ដែលក្នុងនោះមាន ១២៣ រោងចក្រ សហគ្រាស គ្រឹះស្ថាន ហើយមានអ្នកចូលរួមសរុបចំនួន ៤.២៧៥ នាក់ ។

ការសម្រេចបាននូវលទ្ធផលការងារខាងលើ របស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ដោយសារមានការជួយជ្រោមជ្រែង គាំទ្រសហការ ពីក្រសួង អង្គការជាតិ អន្តរជាតិ ស្ថាប័នពាក់ព័ន្ធនានា និងមានការចូលរួមអនុវត្តគោរពច្បាប់ចរាចរណ៍បានល្អពីសំណាក់អ្នកបើកបរដឹកកម្មករ និងកម្មករនិយោជិតផងដែរ ជាក់ស្តែងឆមាសទី១ ឆ្នាំ២០១៤ ករណីគ្រោះថ្នាក់ចរាចរណ៍លើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត មានការថយចុះមួយកម្រិតគួរឲ្យកត់សម្គាល់។ ទន្ទឹមនឹងលទ្ធផលការងារខាងលើ ក្រុមការងារ ស.ផ.ក បានសង្កេតឃើញថាមានបញ្ហាមួយចំនួនទៀតដែលអនុវត្តមិនទាន់ល្អប្រសើរ គឺករណីគ្រោះថ្នាក់ក្នុងពេលធ្វើដំណើរកម្មករនិយោជិតដោយម៉ូតូមានកើនឡើងផងដែរជាពិសេសមិនមានការប្រើប្រាស់មួកសុវត្ថិភាពបានត្រឹមត្រូវ ។

ដូច្នេះ ទាមទារឲ្យមានការបន្តជួយយកចិត្តទុកដាក់ គាំទ្រសហការបន្ថែមទៀតលើការគោរពច្បាប់ចរាចរណ៍ ការមិនប្រើប្រាស់គ្រឿងស្រវឹងពេលបើកបរ បើកបរដោយមានការប្រុងប្រយ័ត្ន ការប្រើប្រាស់មួកសុវត្ថិភាព ពីសំណាក់បងប្អូនអ្នកបើកបរដឹកកម្មករ និងកម្មករនិយោជិត ដើម្បីធានាបាននូវសុវត្ថិភាពក្នុងការធ្វើដំណើររបស់បងប្អូនកម្មករនិយោជិត ចូលរួមលើកកម្ពស់សុវត្ថិភាពចរាចរណ៍ អភិវឌ្ឍសេដ្ឋកិច្ចសង្គម និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់កម្មករនិយោជិត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

## ៩.ឯកសារយោង

- របាយការណ៍របស់បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ២០១៤
- របាយការណ៍ក្រសួងមហាផ្ទៃ (នាយកដ្ឋានសណ្តាប់ធ្នាប់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ)
- ទិន្នន័យក្រុមការងារ ស.ផ.ក

## ១០.ទំនាក់ទំនងផ្ទាល់

### ០១-ប.ស.ស

-លេខទូរស័ព្ទ៖ **១២៨៦**

| | | |
|---|---|---|
| ០២៣ ៨៨២ ៦២៣ | / | ០២៣ ៨៨២ ៤៣៤ |
| ០២៣ ៩៩៨ ៤១៩ | / | ០២៣ ៩៩៨ ៤១៨ |
| ០២៣ ៨៨២ ៦២៣ | / | ០២៣ ៩៩៨ ៤១៧ |
| ០២៣ ៨៨១ ១៧៦ | / | ០២៣ ៧២២ ៣០៨ |
| ០២៣ ៧២២ ៣០៧ | / | ០២៣ ៧២២ ៣៧៨ |
| ០២៣ ៧២២ ៣៧៩ | / | ០២៣ ៧២២ ៣៩០ |
| ០២៣ ៨៨១ ១៣៩ | / | ០២៣ ៨៨២ ៤៣៤ |

-គេហទំព័រ (Website) ៖ www.nssf.gov.kh

-សារអេឡិចត្រូនិច (E-mail)៖ info@nssf.gov.kh

-Page Facebook៖ **បេឡាជាតិរបបសន្តិសុខសង្គម**

### ០២-សមាសភាពក្រុមការងារស.ផ.ក៖

| | | | |
|---|---|---|---|
| - លោក ព្រាប ច័ន្ទវិបុល | អនុប្រធាន | លេខទូរស័ព្ទ | ០១១ ៩០៩ ១៤៦ |
| - លោក លោក នាង ភារិទ្ធ | អនុប្រធាន | លេខទូរស័ព្ទ | ០១២ ៥៩១ ៧៧៧ |
| - ឧត្តមសេនីយ៍ត្រី លុយ ឈីន | អនុប្រធាន | លេខទូរស័ព្ទ | ០១២ ៨៤០ ១២២ |
| - លោក ជាវ ប៊ុនរិទ្ធ | សមាជិក | លេខទូរស័ព្ទ | ០៧៧ ៩៩៩ ០៧៨ |
| - លោកស្រី បុប្ផា ផានី | សមាជិក | លេខទូរស័ព្ទ | ០៩០ ៩១៨ ៨៨៨ |
| - លោក ហុក ហួលីម | សមាជិក | លេខទូរស័ព្ទ | ០១២ ៩៧៥ ៩៩៣ |
| - លោកវរសេនីយ៍ត្រី ម៉ក់ ណារិទ្ធ | សមាជិក | លេខទូរស័ព្ទ | ០៩២ ១៦៨ ៣៨៦ |
| - លោកស្រី ប៉ែន សក្ខនី | សមាជិក | លេខទូរស័ព្ទ | ០១២ ៤៤៩ ៧៣៤ |
| - លោក កាំង មុនីកា | សមាជិក | លេខទូរស័ព្ទ | ០១២ ៦០២ ២២២ |
| - លោក សោម អូន | សមាជិក | លេខទូរស័ព្ទ | ០១២ ៨៦៦ ៦៨២ |
| - លោក គង់ អាទិត្យ | សមាជិក | លេខទូរស័ព្ទ | ០១២ ៧០៩ ៥០៩ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម
លេខ : ១២/១៤ ប.ស.ស /ស.ជន

# ផែនការសកម្មភាពឆ្នាំ២០១៥ របស់ក្រុមការងារសុវត្ថិភាព ចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត

## សេចក្តីផ្តើម៖

គ្រោះថ្នាក់ចរាចរណ៍ ជាឃាតករលាក់មុខដែលបានបណ្តាលឲ្យមនុស្សស្លាប់ និងរងរបួស ពិការជាច្រើននាក់ជារៀងរាល់ថ្ងៃ ។ ជាក់ស្តែងផ្អែកតាមរបាយការណ៍សកលឆ្នាំ២០១៣កន្លងទៅនេះគ្រោះថ្នាក់ចរាចរណ៍បានធ្វើឲ្យមនុស្សប្រមាណជាជាង ១.២៤លាននាក់ បានស្លាប់ និងពី២០ ទៅ ៥០ លាននាក់ផ្សេងទៀត រងរបួស នៅលើដងផ្លូវទូទាំងពិភពលោកជារៀងរាល់ឆ្នាំ។ មានន័យថាជាមធ្យមមនុស្សប្រមាណជាជាង ៣.០០០នាក់ នៅលើពិភពលោក បានស្លាប់បាត់បង់អាយុជីវិតជារៀងរាល់ថ្ងៃ ដោយសារគ្រោះថ្នាក់ចរាចរណ៍ ។ គ្រោះថ្នាក់ចរាចរណ៍ ភាគច្រើនកើតឡើងក្នុងប្រទេសក្រីក្រ និងកំពុងអភិវឌ្ឍន៍។ ផលប៉ះពាល់នៃគ្រោះថ្នាក់ចរាចរណ៍ បានធ្វើឲ្យប្រទេសទាំងនោះ ខាតបង់ផ្នែកសេដ្ឋកិច្ច គិតជាថវិកាសរុបប្រមាណជាង១០០ពាន់លានដុល្លារសហរដ្ឋអាមេរិក ជារៀងរាល់ឆ្នាំ ។

តាមរបាយការណ៍របស់នាយកដ្ឋានសណ្តាប់ធ្នាប់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ (គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ ដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៤) បានបង្ហាញឲ្យឃើញថាក្នុងឆមាសទី១ ឆ្នាំ២០១៤ នេះមានករណីគ្រោះថ្នាក់ចរាចរណ៍ដោយរថយន្តដឹកកម្មករមានចំនួន៣ ករណី ។ ក្នុងនោះបង្កឡើងដោយរថយន្តដឹកកម្មករចំនួន ២ករណី (ផ្ទុះកង់ និងប្រជែងក្នុងស្ថានភាពគ្រោះថ្នាក់) និង ១ ករណីទៀតបង្កឡើងដោយរថយន្តធំបើកបុកដោយមិនគោរពសិទ្ធអាទិភាព បណ្តាលឲ្យមានជនរងគ្រោះសរុបចំនួន១១០ នាក់ ក្នុងនោះដែរទទួលរងរបួសធ្ងន់២៣ នាក់ និងរបួសស្រាលចំនួន៨៧ នាក់ ។

ចំណាំ៖ ក្នុងចំណោមអ្នកស្លាប់៣២ នាក់ មិនមានអ្នកបាត់បង់ជីវិតដោយសារករណីយានយន្តដឹកកម្មករនោះទេ (យោងតាមរបាយការណ៍នាយកដ្ឋានសណ្តាប់ធ្នាប់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ)

ដោយឡែកបច្ចុប្បន្ននេះ គ្រោះថ្នាក់ចរាចរណ៍ចំពោះកម្មករនិយោជិតនៅតែមានការកើតឡើងគួរឲ្យព្រួយបារម្ភ។ យោងរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់បេឡាជាតិរបបសន្តិសុខសង្គម បង្ហាញឲ្យឃើញថានៅឆមាសទី១ ឆ្នាំ២០១៤ កន្លងមកនេះ មានគ្រោះថ្នាក់ចរាចរណ៍បានកើត



អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៤ , ០២៣ ៩៩ ៨៤ ១៧ ០២៣-៩៩ ៨៤ ១៨ , ០២៣ ៩៩ ៨៤ ១៩
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh

ឡើង ចំនួន ២,០៣៣ ករណី ដែលបណ្តាលឲ្យបងប្អូនកម្មករនិយោជិតទទួលរងគ្រោះថ្នាក់រហូតដល់ស្លាប់ ចំនួន ៣២ នាក់ របួសធ្ងន់ ចំនួន ៤៥៤ នាក់ និងរបួសស្រាល ចំនួន ២,០៤៨ នាក់ ។

អនុលោមតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងស្របតាមស្មារតីអង្គប្រជុំអន្តរក្រសួង និងស្ថាប័នពាក់ព័ន្ធ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីសម្រេចលេខ០០២ កប/ស.ស.រ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ស្តីពីការបង្កើត "ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត" ហៅកាត់ថា "ស.ផ.ក" ។ ក្រុមការងារនេះ បានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនដោយបានរៀបចំផែនការសកម្មភាព និងអនុវត្តការងារឆ្នាំ២០១៤ និងបន្តរៀបចំផែនការសកម្មភាពការងារសម្រាប់ឆ្នាំ២០១៥ សំដៅរួមចំណែកកាត់បន្ថយ និងទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍របស់បងប្អូនកម្មករនិយោជិតឲ្យនៅកម្រិតទាបបំផុត ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើនេះ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត បានរៀបចំវិធានការទប់ស្កាត់ករណីគ្រោះថ្នាក់ពេលធ្វើដំណើរ របស់កម្មករនិយោជិតដោយធ្វើការសហការជាមួយស្ថាប័នពាក់ព័ន្ធ ណែនាំ ផ្សព្វផ្សាយអប់រំបន្តដល់បងប្អូនកម្មករនិយោជិត និងអ្នកបើកបររថយន្តដឹកកម្មករ ។ ការផ្សព្វផ្សាយអប់រំធ្វើឡើងដោយផ្តោតទៅលើខ្លឹមសារចម្បងៗ ដូចជាការយល់ដឹងអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ការបង្ការគ្រោះថ្នាក់ចរាចរណ៍ ការថែទាំយានយន្ត និង ការសង្គ្រោះបឋម ។ តាមរយៈផែនការសកម្មភាពការងារឆ្នាំ២០១៥ នេះ ក្រុមការងារ ស.ផ.ក ជឿជាក់ថាក្នុងកិច្ចដំណើរការនៃការអនុវត្តន៍តួនាទីភារកិច្ចរបស់ខ្លួន នឹងទទួលបានលទ្ធផលមួយដែលអាចទទួលយកបានពោលគឺ អ្នកបើកបរ និងកម្មករនិយោជិត ចូលរួមគោរពច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

**ក. ចក្ខុវិស័យ ៖**

រួមចំណែកទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ចំពោះកម្មករនិយោជិត។

**ខ. គោលបំណង ៖**

អនុវត្តស្របតាមជំហាន របបធានារ៉ាប់រងហានិភ័យការងារ នៃ ប.ស.ស ក្នុងផែនការបង្ការគ្រោះថ្នាក់ដែលកើតឡើងពីការងារ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិតខិតខំអនុវត្តតាមតួនាទីភារកិច្ច ដើម្បីចូលរួមទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ដែលកើតមានមកលើកម្មករនិយោជិត តាមរយៈការរៀបចំផ្សព្វផ្សាយអប់រំដោយផ្ទាល់នៅនឹងកន្លែង និងតាមប្រព័ន្ធផ្សព្វផ្សាយនានាដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតឲ្យងាកមកគោរពតាមគោលការណ៍ច្បាប់ដែលមានចែងជាធរមាន។

**គ. ទិសដៅអនុវត្ត ៖**

ក្នុងស្មារតីនេះ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត បានដាក់ចេញនូវទិសដៅអនុវត្តការងារសម្រាប់ឆ្នាំ ២០១៥ ដូចខាងក្រោម ៖

- បន្តស្រង់ស្ថិតិមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និងអ្នកបើកបរតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន ទូទាំងប្រទេស
- បន្តសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ វិភាគរកមូលហេតុចម្បងៗ ដែលនាំឲ្យកើតមានគ្រោះថ្នាក់ចរាចរណ៍ ក្នុងពេលធ្វើដំណើររបស់កម្មករនិយោជិត
- បន្តចាត់វិធានការចុះផ្សព្វផ្សាយអប់រំ ណែនាំ ស្តីពីច្បាប់ និងសុវត្ថិភាពចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរ និង កម្មករនិយោជិតនៅតាមបណ្តាសហគ្រាស គ្រឹះស្ថាននានានៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត
- បណ្តុះបណ្តាល និងផ្តល់ប័ណ្ណបើកបរចំពោះអ្នកបើកបរដឹកកម្មករដែលមិនទាន់មាន តាមនីតិវិធីពិសេសអនុញ្ញាតដោយក្រសួងសាធារណៈការ និងដឹកជញ្ជូន
- បន្តសហការជាមួយអាជ្ញាធរ ភាគីពាក់ព័ន្ធ ក្នុងពេលអនុវត្តការងារ
- រៀបចំរបាយការណ៍ការងារ ។

**១. សកម្មភាពអនុវត្តការងារឆ្នាំ២០១៥ ៖**

ដើម្បីសម្រេចទិសដៅការងារខាងលើប្រកបដោយផ្លែផ្កា ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ត្រូវសហការជាមួយ ក្រសួង ស្ថាប័ន អង្គភាព អាជ្ញាធរដែនដីពាក់ព័ន្ធដើម្បីរៀបចំវិធានការទប់ស្កាត់ និងកាត់បន្ថយករណីគ្រោះថ្នាក់ពេលធ្វើដំណើររបស់កម្មករនិយោជិតដូចខាងក្រោម៖

**១.១ - បន្តស្រង់ស្ថិតិមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និងអ្នកបើកបរ តាមរោងចក្រ សហគ្រាស គ្រឹះស្ថាន ទូទាំងប្រទេស**

ដើម្បីសម្រេចការងារនេះទៅបានក្រុមការងារធ្វើផែនការរៀបចំជាជំហានៗ

- ចុះទៅប្រមូលព័ត៌មាន ទិន្នន័យ ប្រភេទមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត ឈ្មោះអ្នកបើកបរ អាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង ពីបណ្តារោងចក្រនីមួយៗ

- ចងក្រងរក្សាទុកឯកសារសម្រាប់ស្រាវជ្រាវ ហើយអាចតាមដានបានថាមានតួអង្គណាខ្លះ បើកបរ នៅពេលមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង និងងាយស្រួលក្នុងពេលដែលក្រុមការងារត្រូវ ការទំនាក់ទំនងជាមួយអ្នកបើកបរមកចូលរួមប្រជុំផ្សព្វផ្សាយអប់រំ ណែនាំអំពីច្បាប់ ស្តីពី ចរាចរណ៍ផ្លូវគោក ការថែទាំយានយន្ត និងការសង្គ្រោះបឋម
- សហការរៀបចំផែនការចុះស្រង់ស្ថិតិ ជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC)
- ចុះស្រង់ស្ថិតិផ្ទាល់ ដោយសមាជិក ស.ផ.ក និងលេខាធិការ ក្នុងករណីដែលចាំបាច់ ។

**១.២ - បន្តសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ វិភាគរកមូលហេតុចម្បងៗ ដែលនាំឲ្យកើតមាន គ្រោះថ្នាក់ចរាចរណ៍ ក្នុងពេលធ្វើដំណើររបស់កម្មករនិយោជិត**

- តាមដានព័ត៌មានគ្រោះថ្នាក់ចរាចរណ៍ជាប្រចាំ
- កំណត់ពីមូលហេតុគ្រោះថ្នាក់ចរាចរណ៍
- រៀបចំចំណាត់ថ្នាក់គ្រោះថ្នាក់ចរាចរណ៍
- ចងក្រងព័ត៌មានគ្រោះថ្នាក់ចរាចរណ៍ ។

**១.៣ បន្តចាត់វិធានការចុះផ្សព្វផ្សាយអប់រំ ណែនាំ ស្តីពីច្បាប់ និងសុវត្ថិភាពចរាចរណ៍ផ្លូវគោកដល់ អ្នកបើកបរ និងកម្មករនិយោជិតនៅតាមបណ្តាសហគ្រាស គ្រឹះស្ថាននានា នៅ រាជធានីភ្នំពេញ និងតាមបណ្តាខេត្ត**

បន្ទាប់ពីបានធ្វើការស្រង់ស្ថិតិ សិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យវិភាគរកមូលហេតុចម្បងៗ បានមក ក្រុមការងារ ស.ផ.ក ចុះផ្សព្វផ្សាយ ណែនាំ ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោកនៅហ្នឹងកន្លែងការងារ និង អញ្ជើញនិយោជក មកចូលរួមប្រជុំផ្សព្វផ្សាយអប់រំ ណែនាំ នៅ ប.ស.ស ។

**១.៣.១ - ផ្សព្វផ្សាយផ្ទាល់នៅកន្លែងធ្វើការ**

- រៀបចំឯកសារបទបង្ហាញ ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក បច្ចេកទេសត្រួតពិនិត្យយាន យន្តប្រចាំថ្ងៃ និងវិជ្ជាសង្គ្រោះបឋម
- រៀបចំខិត្តប័ណ្ណ បដា ពាក្យស្លោក វីដេអូអប់រំខ្លីៗ(ស្តុត)
- សម្របសម្រួលជាមួយរោងចក្រ ដើម្បីស្នើសុំអញ្ជើញអ្នកបើកបរដឹកកម្មករនិយោជិត សហជីព និងប្រតិភូបុគ្គលិក ចូលរួមប្រជុំផ្សព្វផ្សាយអប់រំ
- អញ្ជើញអាជ្ញាធរមូលដ្ឋាន
- ផ្តល់វិញ្ញាបនបត្រជូនសិក្ខាកាម (អ្នកបើកបរដឹកកម្មករនិយោជិត)
- ផ្តល់ជូនជារង្វាន់លើកទឹកចិត្ត (មួកសុវត្ថិភាព) ចំពោះអ្នកបើកបរដែលចូលរួមបាន ឆ្លើយត្រូវសំណួររបស់ក្រុមការងារ
- ផ្សព្វផ្សាយស្មារតីអង្គប្រជុំតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ (វិទ្យុ ទូរទស្សន៍ សារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត) ។

១.៣.២ - ផ្សព្វផ្សាយនៅ ប.ស.ស

និយោជក នាយក ម្ចាស់ ឬតំណាងរោងចក្រ សហគ្រាស គ្រឹះស្ថាននានា ត្រូវបានអញ្ជើញចូលរួមប្រជុំផ្សព្វផ្សាយអប់រំ ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក បច្ចេកទេសត្រួតពិនិត្យយានយន្តប្រចាំថ្ងៃ និងវិជ្ជាសង្គ្រោះបឋម ក្នុងមួយឆមាស ០១លើក ដើម្បីចូលរួមអនុវត្ត និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ។

១.៤ - បណ្តុះបណ្តាលនិងផ្តល់បណ្ណបើកបរចំពោះអ្នកបើកបរដឹកកម្មករ ដែរមិនទាន់មានតាមនីតិវិធីពិសេស ដែលអនុញ្ញាតដោយក្រសួងសាធារណៈការ និងដឹកជញ្ជូន

- សុំគោលការណ៍អនុញ្ញាតពីក្រសួងសាធារណៈការ និងដឹកជញ្ជូន ធ្វើការបណ្តុះបណ្តាលអ្នកបើកបរដឹកកម្មករ
- សហការជាមួយសាលាបង្រៀនបើកបរតាមបណ្តារាជធានី/ខេត្ត
- សហការជាមួយគណៈកម្មការប្រឡង នៃមន្ទីរសាធារណៈការ និងដឹកជញ្ជូន តាមបណ្តារាជធានី/ខេត្ត
- ធ្វើការប្រឡងយកប័ណ្ណបើកបរ និងផ្តល់ប័ណ្ណបើកបរ
- ផ្តល់ការលើកទឹកចិត្តចំពោះអ្នកបើកបរ

១.៥ - សហការជាមួយអាជ្ញាធរ ភាគីពាក់ព័ន្ធ ក្នុងពេលអនុវត្តការងារ

- សហការផ្សព្វផ្សាយអប់រំណែនាំដោយផ្ទាល់នៅនឹងកន្លែងគោលដៅដើមទី (ត្រួតពិនិត្យមុនពេលចេញដំណើរ)
- សហការជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ដើម្បីសម្របសម្រួល និងជម្រុញរោងចក្រឲ្យចុះកិច្ចសន្យាជាមួយម្ចាស់យានយន្តសម្រាប់ធានានូវសុវត្ថិភាពដឹកជញ្ជូនដល់កម្មករនិយោជិត
- សម្របសម្រួល និងជម្រុញដល់រោងចក្រ ដែលមានលទ្ធភាពក្នុងការរៀបចំយន្តការដឹកជញ្ជូនកម្មករនិយោជិត
- ជម្រុញឲ្យមានកិច្ចសន្យាដឹកជញ្ជូនដែលធានាសុវត្ថិភាពចរាចរណ៍រវាងរោងចក្រនិងម្ចាស់យានយន្តដែលដឹកកម្មករនិយោជិត
- សម្របសម្រួលឲ្យមានការបញ្ជ្រាបសុវត្ថិភាពចរាចរណ៍ទៅក្នុងគោលនយោបាយរបស់រោងចក្រ សហគ្រាស។

១.៦ - រៀបចំរបាយការណ៍ការងារ

- របាយការណ៍ឆមាសទី១
- របាយការណ៍ឆមាសទី២
- របាយការណ៍ប្រចាំឆ្នាំ

## ២. សូចនាករ និងលទ្ធផលរំពឹងទុក ៖

អ្នកបើកបរ និងកម្មករនិយោជិត យ៉ាងតិចហុកសិបភាគរយ (៦០%) មានការយល់ដឹងកាន់តែប្រសើរ និងចូលរួមគោរពច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងទប់ស្កាត់ កាត់បន្ថយអ្នកស្លាប់ ដោយគ្រោះថ្នាក់ចរាចរណ៍ យ៉ាងតិចដប់ភាគរយ (១០%) ។

**៣. សេចក្តីសន្និដ្ឋាន ៖**

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត សហការជាមួយ ក្រសួង ស្ថាប័ន អង្គភាព អាជ្ញាធរពាក់ព័ន្ធ តាមរយៈការអនុវត្តផែនការសកម្មភាពការងារឆ្នាំ២០១៥នេះ ថ្វីត្បិតតែ ករណីគ្រោះថ្នាក់ចរាចរណ៍នៅតែជាក្តីកង្វល់របស់រាជរដ្ឋាភិបាលក៏ដោយ ក៏យើងជឿជាក់យ៉ាងមុតមាំថា នឹងអាចជួយធ្វើឲ្យប្រសើរឡើងនូវសុវត្ថិភាពក្នុងការធ្វើដំណើររបស់បងប្អូនកម្មករនិយោជិត ជាពិសេស ចូលរួមជួយលើកកម្ពស់សុវត្ថិភាព អភិវឌ្ឍសេដ្ឋកិច្ចសង្គម និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់កម្មករ និយោជិត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៤

**ប្រធានការិ.គ.ន.ប និងជាសមាជិក ស.ជ.ក**

**ជាវ_ប៊ុនរិទ្ធ**

បានឃើញ និងឯកភាព

ថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ២០១៤

**នាយក ប.ស.ស និងជាប្រធាន ស.ជ.ក**

**អ៊ុក_សមវិទ្យា**

PC 31602 D

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

**អគ្គស្នងការដ្ឋាននគរបាលជាតិ**

**សេនាធិការដ្ឋាន**

# កំណត់បង្ហាញ

យោងលិខិតលេខ : 2163 កប ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤

របស់ស្ថាប័ន : ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សង្ខេបខ្លឹមសារ : ការស្នើសុំកិច្ចសហការជាមួយអធិការដ្ឋាននគរបាលខណ្ឌ/ស្រុក នៃស្នងការនគរបាល រាជធានី ខេត្ត ទាំង២៥ ដើម្បីចុះផ្សព្វផ្សាយអប់រំស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក, បច្ចេកទេសត្រួតពិនិត្យយានយន្ត និងវិជ្ជាសង្គ្រោះបឋមដល់អ្នកបើកដឹកកម្មករនៅតាមមូលដ្ឋានរោងចក្រដែលមានអ្នកបើកបរច្រើន ដែលគ្រោងនឹងចុះផ្សព្វផ្សាយនៅខែមករា ឆ្នាំ២០១៥។

មតិសេនាធិការដ្ឋាន : សូមអនុញ្ញាតជូន ឯកឧត្តម យុន ឈុន្នី អគ្គស្នងការរងនគរបាលជាតិ និងលោកស្នងការនគរបាល រាជធានី ខេត្ត ដើម្បីជាសមត្ថកិច្ច។

ដោយសេចក្តីគោរព ។

រាជធានីភ្នំពេញ, ថ្ងៃទី 17 ខែ 11 ឆ្នាំ ២០១៤

**ប្រធានសេនាធិការ**

ឧត្តមសេនីយ៍ឯក.ឆាយ_គីមខឿន

19/11/14

នាយឧត្តមសេនីយ៍.យុន_ឈុន្នី

| **អគ្គស្នងការនគរបាលជាតិ** | **អគ្គស្នងការរងទទួលផែន** |
| --- | --- |
| 19/11/14<br>នាយឧត្តមសេនីយ៍.នេត_សាវឿន | |

១៧-វិច្ឆិកា-២០១៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

អគ្គស្នងការដ្ឋាននគរបាលជាតិ

នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ

លេខ ៤០១/១៤..........

ភ្នំពេញ,ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១......

**ជំរាបជូន**

**លោកស្នងការនគរបាលខេត្តទាំង២៤**

**កម្មវត្ថុ** : ស្តីពីការចាត់មន្ត្រីជំនាញនគរបាលចរាចរណ៍ផ្លូវគោកខណ្ឌ/ស្រុក ចូលរួមសហការណ៍ជាមួយ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**យោង** :-លិខិតលេខ២១៦៣កប.ចុះថ្ងៃទី១៤ខែវិច្ឆិកាឆ្នាំ២០១៤ របស់ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ។

-ចំណារឯកឧត្តម នាយឧត្តមសេនីយ៍អគ្គស្នងការនគរបាលជាតិ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ សូមជម្រាបជូនលោកស្នងការនគរបាលខេត្តមេត្តាជ្រាបថា : ដើម្បីពង្រឹងការអនុវត្តន៏ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតនៅតាមរោងចក្រ ឈានទៅកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ដែលបង្កឡើងដោយអ្នកបើកបរយានយន្តដឹកកម្មករនិយោជិត នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ សូមលោកស្នងការនគរបាលខេត្ត ចាត់មន្ត្រីជំនាញនគរបាលចរាចរណ៍ផ្លូវគោកខណ្ឌ/ស្រុកចូលរួមសហការជាមួយ ក្រុមសុវត្ថិភាពចរាចរណ៍ផ្លូវគោក សំរាប់គាំពារកម្មករនិយោជិត នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះបង្រៀនច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរដឹកកម្មករនិយោជិត ចាប់ពីខែមករាឆ្នាំ២០១៥តទៅ ។

អាស្រ័យហេតុនេះ សូមលោកស្នងការនគរបាលខេត្ត មេត្តាចាត់ចូលរួមអនុវត្តតាមស្មារតីខាងលើ តាមការគួរ ។

**ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ**

ឧត្តមសេនីយ៍ឯក.**ហ៊ឹម_យ៉ាន**

*ចំលងជូន*

-នាយកដ្ឋានសណ្តាប់ធ្នាប់ ( សហការអនុវត្តន៏ )

ឯកសារ កាលប្បវត្តន៏

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គស្នងការដ្ឋាននគរបាលជាតិ
នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ
លេខ ២០០/១៤..........

ភ្នំពេញ,ថ្ងៃទី២៥ខែវិច្ឆិកា ឆ្នាំ២០១......

## គោរពជូន
## ឯកឧត្តម អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញ

**កម្មវត្ថុ** : ស្តីពីការចាត់មន្ត្រីជំនាញនគរបាលចរាចរណ៍ផ្លូវគោកខណ្ឌ/ស្រុក ចូលរួមសហការណ៍ជាមួយ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**យោង** :-លិខិតលេខ២១៦៣កប.ចុះថ្ងៃទី១៤ខែវិច្ឆិកាឆ្នាំ២០១៤ របស់ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ។
-ចំណារឯកឧត្តម នាយឧត្តមសេនីយ៍អគ្គស្នងការនគរបាលជាតិ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ សូមគោរពឯកឧត្តម អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញមេត្តាជ្រាបថា : ដើម្បីពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតនៅតាមរោងចក្រឈានទៅកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ដែលបង្កឡើងដោយអ្នកបើកបរយានយន្តដឹកកម្មករនិយោជិត សូមឯកឧត្តមមេត្តាចាត់មន្ត្រីជំនាញនគរបាលចរាចរណ៍ផ្លូវគោកខណ្ឌ/ស្រុកចូលរួមសហការជាមួយក្រុមសុវត្ថិភាពចរាចរណ៍ផ្លូវគោកសំរាប់គាំពារកម្មករនិយោជិត នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចុះបង្រៀនច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរដឹកកម្មករនិយោជិតចាប់ពីខែមករាឆ្នាំ២០១៥តទៅ។

អាស្រ័យហេតុនេះ សូមឯកឧត្តម អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញមេត្តាចាត់ចូលរួមអនុវត្តតាមស្មារតីខាងលើតាមការគួរ ។

**ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ**

ឧត្តមសេនីយ៍ឯក.ហ៊ឹម_យ៉ាន

*ចំលងជូន*
-នាយកដ្ឋានសណ្តាប់ធ្នាប់ ( សហការអនុវត្តន៍ )
ឯកសារ កាលប្បវត្តន៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន

លេខ: ៤៤៣៥ សក

ភ្នំពេញ,ថ្ងៃទី ១៩ ខែ ៥ ឆ្នាំ ២០១៤

**គោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**កម្មវត្ថុ** ៖ ករណីស្នើសុំការប្រឡង និងផ្តល់បណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត នៅតាមមូលដ្ឋានរោងចក្រប្រមូលផ្តុំអ្នកបើកបរ។

**យោង** ៖ លិខិតលេខ ២១៦២ ក.ប ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកបើកបររថយន្តដឹកកម្មករនិយោជិតនៅតាមរោងចក្រអាចទទួលបណ្ណបើកបរបានស្របតាមច្បាប់កំណត់ ក្រសួងសាធារណការ និងដឹកជញ្ជូន សូមឯកភាពតាមសំណើរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការរៀបចំប្រឡង និងផ្តល់បណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត នៅតាមមូលដ្ឋានរោងចក្រប្រមូលផ្តុំ ដោយអនុវត្តតាមនីតិវិធីនៃការបណ្តុះបណ្តាលប្រឡង និងផ្តល់បណ្ណបើកបរ ដែលមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត សហការជាមួយក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត(ស.ផ.ក) ក្នុងការអនុវត្តផ្ទាល់នៅតាមមូលដ្ឋានរោងចក្រដែលមានការប្រមូលផ្តុំអ្នកបើកបរច្រើន។

ន័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាប តាមការគួរ។

សូម **ឯកឧត្តម** ទទួលនូវការគោរពរាប់អាន អំពីខ្ញុំ។

រដ្ឋមន្ត្រី
ជ.រដ្ឋលេខាធិការ

ម៉ិន-ម៉ាណាវី

**កន្លែងទទួល** ៖

- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត
  «ដើម្បីមុខការ»
- ឯកសារ - កាលប្បវត្តិ

ក្រសួងមហាផ្ទៃ
អគ្គស្នងការដ្ឋាននគរបាលជាតិ
នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ
នាយកដ្ឋានសណ្តាប់ធ្នាប់
លេខ: ១០៧៩ ស.ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ទិន្នន័យគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក

## ប្រចាំ ឆ្នាំ២០១៤ ចាប់ពីថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៣ ដល់ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៤

| ល.រ | រាជធានី-ខេត្ត | គ្រោះថ្នាក់ | ស្លាប់ | | | របួសធ្ងន់ | | | របួសស្រាល | | | យានយន្តការខូចខាត | | | | ថ្មើរជើង | មិនពាក់មួក |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | លើក | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | ម៉ូតូ | ឡានស្រាល | ឡានធ្ងន់ | យានផ្សេងៗ | នាក់ | ពេលគ្រោះថ្នាក់ |
| ១ | បន្ទាយមានជ័យ | 308 | 129 | 108 | 21 | 268 | 204 | 64 | 208 | 140 | 68 | 315 | 151 | 46 | 32 | 20 | 283 |
| ២ | បាត់ដំបង | 260 | 106 | 88 | 18 | 258 | 187 | 71 | 182 | 142 | 40 | 274 | 99 | 30 | 30 | 25 | 155 |
| ៣ | កំពង់ចាម | 342 | 165 | 129 | 36 | 276 | 209 | 67 | 250 | 185 | 65 | 380 | 91 | 36 | 18 | 63 | 174 |
| ៤ | កំពង់ឆ្នាំង | 230 | 105 | 88 | 17 | 207 | 165 | 42 | 242 | 164 | 78 | 246 | 54 | 46 | 20 | 30 | 326 |
| ៥ | កំពង់ស្ពឺ | 132 | 93 | 82 | 11 | 140 | 113 | 27 | 66 | 48 | 18 | 143 | 46 | 30 | 5 | 14 | 179 |
| ៦ | កំពង់ធំ | 136 | 101 | 90 | 11 | 105 | 83 | 22 | 72 | 41 | 31 | 116 | 37 | 48 | 26 | 18 | 155 |
| ៧ | កំពត | 262 | 81 | 63 | 18 | 340 | 253 | 87 | 148 | 115 | 33 | 325 | 57 | 13 | 27 | 40 | 386 |
| ៨ | កណ្តាល | 252 | 166 | 141 | 25 | 234 | 182 | 52 | 173 | 128 | 45 | 284 | 79 | 51 | 13 | 27 | 367 |
| ៩ | កោះកុង | 124 | 17 | 15 | 2 | 78 | 63 | 15 | 122 | 80 | 42 | 122 | 37 | 15 | 6 | 9 | 86 |
| ១០ | ក្រចេះ | 180 | 118 | 94 | 24 | 180 | 135 | 45 | 51 | 28 | 23 | 169 | 76 | 20 | 11 | 41 | 122 |
| ១១ | មណ្ឌលគីរី | 54 | 21 | 19 | 2 | 80 | 69 | 11 | 28 | 20 | 8 | 42 | 22 | 8 | 3 | 2 | 34 |
| ១២ | រាជធានីភ្នំពេញ | 633 | 241 | 215 | 26 | 568 | 510 | 58 | 251 | 204 | 47 | 597 | 407 | 78 | 48 | 46 | 464 |
| ១៣ | ព្រះវិហារ | 94 | 61 | 48 | 13 | 112 | 75 | 37 | 68 | 41 | 27 | 88 | 31 | 7 | 9 | 10 | 121 |
| ១៤ | ព្រៃវែង | 304 | 127 | 108 | 19 | 324 | 242 | 82 | 188 | 138 | 50 | 344 | 92 | 50 | 49 | 51 | 396 |
| ១៥ | ពោធិសាត់ | 218 | 80 | 64 | 16 | 200 | 141 | 59 | 163 | 107 | 56 | 206 | 50 | 33 | 16 | 25 | 112 |
| ១៦ | រតនគីរី | 105 | 46 | 34 | 12 | 96 | 77 | 19 | 58 | 47 | 11 | 102 | 38 | 17 | 15 | 8 | 60 |
| ១៧ | សៀមរាប | 135 | 85 | 70 | 15 | 128 | 92 | 36 | 96 | 67 | 29 | 117 | 54 | 37 | 15 | 22 | 74 |
| ១៨ | ព្រះសីហនុ | 206 | 84 | 75 | 9 | 184 | 140 | 44 | 210 | 141 | 69 | 218 | 103 | 42 | 1 | 21 | 175 |
| ១៩ | ស្ទឹងត្រែង | 86 | 30 | 26 | 4 | 62 | 50 | 12 | 106 | 84 | 22 | 89 | 37 | 4 | 6 | 4 | 102 |
| ២០ | ស្វាយរៀង | 170 | 73 | 65 | 8 | 204 | 136 | 68 | 228 | 116 | 112 | 197 | 35 | 28 | 15 | 9 | 170 |
| ២១ | តាកែវ | 303 | 103 | 84 | 19 | 303 | 249 | 54 | 258 | 190 | 68 | 342 | 106 | 28 | 39 | 20 | 127 |
| ២២ | ឧត្តរមានជ័យ | 121 | 50 | 46 | 4 | 121 | 93 | 28 | 111 | 71 | 40 | 130 | 33 | 8 | 14 | 13 | 141 |
| ២៣ | កែប | 73 | 19 | 16 | 3 | 80 | 61 | 19 | 44 | 32 | 12 | 82 | 17 | 4 | 4 | 8 | 70 |
| ២៤ | ប៉ៃលិន | 57 | 17 | 16 | 1 | 40 | 34 | 6 | 51 | 40 | 11 | 70 | 24 | 3 | 2 | 4 | 70 |
| ២៥ | ត្បូងឃ្មុំ | 55 | 30 | 21 | 9 | 66 | 51 | 15 | 29 | 22 | 7 | 58 | 21 | 5 | 6 | 8 | 77 |
| | សរុបរួម | 4840 | 2148 | 1805 | 343 | 4654 | 3614 | 1040 | 3403 | 2391 | 1012 | 5056 | 1797 | 687 | 430 | 538 | 4426 |

បានឃើញ និងឯកភាព
រាជធានីភ្នំពេញ.ថ្ងៃទី.១៩.....ខែ វិច្ឆិកា ឆ្នាំ២០១៤
ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់
ឧត្តមសេនីយ៍ទោ.អែល_សំណាង

រាជធានីភ្នំពេញ.ថ្ងៃទី.១៥.....ខែ វិច្ឆិកា ឆ្នាំ២០១៤
អ្នកត្រួតពិនិត្យតារាង
វរសេនីយ៍ឯក. សុខ_ណារុម

រាជធានីភ្នំពេញ.ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០១៤
អ្នកធ្វើតារាង
វរសេនីយ៍ត្រី ង៉ែត_សំរិទ្ធ

# មូលហេតុគ្រោះថ្នាក់ចរាចរណ៍ប្រចាំ ឆ្នាំ២០១៤

| ល.រ | រាជធានី-ខេត្ត | ល្បើសល្បឿន | មិនគោរពភ្លើងសញ្ញ | មិនគោរពសិទ្ធអទិ | មិនប្រកាន់ស្តាំ | ប្រជែងគ្រោះថ្នាក់ | បត់ឆ្វេង-ស្តាំមិនប្រ | ស្រវឹង | ប្រើគ្រឿងញៀន | សុខភាពងងុយដេក | ប្រើប្រាស់ទូរស័ព្ទដៃ | ប្រើភ្លើងហ្វាខុស | ផ្សេងៗ | កត្តាផ្លូវ | កត្តាយានយន្ត | កត្តាអាកាសធាតុ | ចំនួនលើក |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | 125 | 1 | 44 | 8 | 53 | 25 | 34 | 0 | 1 | 0 | 0 | 5 | 2 | 5 | 5 | 308 |
| ២ | បាត់ដំបង | 107 | 0 | 14 | 34 | 20 | 35 | 28 | 0 | 3 | 0 | 3 | 14 | 1 | 0 | 1 | 260 |
| ៣ | កំពង់ចាម | 193 | 3 | 29 | 1 | 32 | 31 | 46 | 0 | 0 | 0 | 0 | 0 | 0 | 7 | 0 | 342 |
| ៤ | កំពង់ឆ្នាំង | 89 | 0 | 50 | 3 | 25 | 11 | 25 | 0 | 5 | 0 | 1 | 6 | 3 | 12 | 0 | 230 |
| ៥ | កំពង់ស្ពឺ | 54 | 0 | 24 | 0 | 29 | 0 | 24 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 132 |
| ៦ | កំពង់ធំ | 33 | 0 | 6 | 16 | 24 | 15 | 20 | 0 | 6 | 0 | 0 | 1 | 7 | 8 | 0 | 136 |
| ៧ | កំពត | 67 | 0 | 9 | 3 | 63 | 44 | 48 | 0 | 0 | 0 | 0 | 10 | 1 | 17 | 0 | 262 |
| ៨ | កណ្តាល | 96 | 7 | 50 | 26 | 34 | 1 | 22 | 0 | 3 | 0 | 0 | 11 | 0 | 2 | 0 | 252 |
| ៩ | កោះកុង | 48 | 2 | 16 | 10 | 12 | 8 | 15 | 0 | 3 | 0 | 0 | 6 | 2 | 2 | 0 | 124 |
| ១០ | ក្រចេះ | 66 | 0 | 52 | 1 | 15 | 8 | 29 | 0 | 4 | 0 | 0 | 2 | 0 | 3 | 0 | 180 |
| ១១ | មណ្ឌលគិរី | 39 | 0 | 3 | 0 | 0 | 0 | 3 | 0 | 0 | 0 | 0 | 1 | 4 | 4 | 0 | 54 |
| ១២ | រាជធានីភ្នំពេញ | 242 | 0 | 101 | 123 | 46 | 3 | 87 | 0 | 1 | 0 | 0 | 21 | 1 | 8 | 0 | 633 |
| ១៣ | ព្រះវិហារ | 46 | 0 | 7 | 4 | 5 | 4 | 24 | 0 | 1 | 0 | 0 | 1 | 1 | 1 | 0 | 94 |
| ១៤ | ព្រៃវែង | 213 | 0 | 7 | 2 | 13 | 22 | 29 | 0 | 0 | 0 | 0 | 4 | 2 | 11 | 1 | 304 |
| ១៥ | ពោធិសាត់ | 150 | 0 | 16 | 18 | 6 | 4 | 9 | 0 | 2 | 0 | 0 | 2 | 4 | 7 | 0 | 218 |
| ១៦ | រតនគិរី | 25 | 0 | 16 | 8 | 13 | 3 | 28 | 0 | 1 | 0 | 0 | 4 | 0 | 7 | 0 | 105 |
| ១៧ | សៀមរាប | 74 | 0 | 13 | 8 | 12 | 6 | 14 | 0 | 1 | 0 | 0 | 6 | 0 | 1 | 0 | 135 |
| ១៨ | ព្រះសីហនុ | 103 | 1 | 11 | 8 | 24 | 26 | 18 | 0 | 3 | 0 | 0 | 6 | 0 | 6 | 0 | 206 |
| ១៩ | ស្ទឹងត្រែង | 28 | 0 | 8 | 7 | 6 | 13 | 12 | 0 | 1 | 0 | 0 | 2 | 0 | 9 | 0 | 86 |
| ២០ | ស្វាយរៀង | 45 | 0 | 20 | 7 | 12 | 28 | 45 | 0 | 4 | 0 | 0 | 6 | 0 | 3 | 0 | 170 |
| ២១ | តាកែវ | 161 | 3 | 42 | 16 | 45 | 3 | 20 | 0 | 3 | 0 | 0 | 3 | 1 | 6 | 0 | 303 |
| ២២ | ឧត្តរមានជ័យ | 56 | 0 | 29 | 6 | 13 | 9 | 8 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 121 |
| ២៣ | កែប | 29 | 0 | 6 | 2 | 3 | 13 | 9 | 0 | 0 | 0 | 0 | 8 | 0 | 2 | 1 | 73 |
| ២៤ | ប៉ៃលិន | 18 | 1 | 12 | 2 | 4 | 4 | 9 | 0 | 3 | 0 | 0 | 2 | 0 | 2 | 0 | 57 |
| ២៥ | ត្បូងឃ្មុំ | 11 | 3 | 10 | 5 | 3 | 5 | 12 | 0 | 0 | 0 | 0 | 2 | 2 | 2 | 0 | 55 |
| សរុបរួម | | 2118 | 21 | 595 | 318 | 512 | 321 | 618 | 0 | 45 | 0 | 4 | 124 | 31 | 125 | 8 | 4840 |
| ចំនួនភាគរយ | | 44% | 0% | 12% | 7% | 11% | 7% | 13% | 0% | 1% | 0% | 0% | 3% | 1% | 3% | 0% | 100% |

រាជធានីភ្នំពេញ.ថ្ងៃទី...១៨....ខែ វិច្ឆិកា ឆ្នាំ២០១៤

**ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ទោ.អ៊ែល_សំនាង

# តារាងប្រៀបធៀប

## រយៈពេល ដូចគ្នា ( ឆ្នាំ២០១៤ - ២០១៣ )

| ល.រ | មុខសញ្ញា | ឯកត្តា | ប្រចាំ ឆ្នាំ២០១៤ | ប្រចាំ ឆ្នាំ២០១៣ | កើនឡើង / ថយចុះ | គិតជាភាគរយ |
|---|---|---|---|---|---|---|
| ១ | ចំនួនគ្រោះថ្នាក់ | លើក | 4840 | 4322 | 518 | 12% |
| ២ | ចំនួនអ្នកស្លាប់ | នាក់ | 2148 | 1901 | 247 | 13% |
| ៣ | ចំនួនអ្នករបួសធ្ងន់ | នាក់ | 4654 | 4205 | 449 | 11% |
| ៤ | ចំនួនអ្នករបួសស្រាល | នាក់ | 3403 | 3003 | 400 | 13% |
| ៥ | ចំនួនម៉ូតូខូចខាត | គ្រឿង | 5056 | 4423 | 633 | 14% |
| ៦ | ចំនួនរថយន្តតូចខូចខាត | គ្រឿង | 1797 | 1713 | 84 | 5% |
| ៧ | ចំនួនរថយន្តធំខូចខាត | គ្រឿង | 687 | 541 | 146 | 27% |
| ៨ | ចំនួនយានផ្សេងៗខូចខាត | គ្រឿង | 430 | 345 | 85 | 25% |
| ៩ | ចំនួនអ្នកថ្មើរជើងរងគ្រោះ | នាក់ | 538 | 623 | -85 | -14% |
| ១០ | មិនពាក់មួកពេលគ្រោះថ្នាក់ | នាក់ | 4426 | 2296 | 2130 | 93% |

# ១២៨៦ លេខទូរស័ព្ទបន្ទាន់ (គ្រោះថ្នាក់ការងារ)

<u>គ្រោះថ្នាក់ការងារ៖</u> ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិត ដោយធ្វើការ ឬក្នុងពេលធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយហើយទោះមានកំហុសពីកម្មករនិយោជិត ឬគ្មានក៏ដោយ ឥ គ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិតក្នុងពេលធ្វើការឲ្យនិយោជក ឬនាយក សហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈមានឈ្នួលក្ដី គាន់មុខងារជាអ្វី នៅទីកន្លែងណាក៏ដោយ។












អាសយដ្ឋាន: អគារ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

(បរិវេណក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ)

ទូរស័ព្ទ: ០២៣ ៨៨ ២៤ ៣៤ / ៩៩ ៨៤ ១៧ / ៩៩ ៨៤ ១៨ / ៩៩ ៨៨ ១៩

ទូរសារ: ០២៣ ៨៨ ២៦ ២៣ Website: www.nssf.gov.kh E-mail: info@nssf.gov.kh

Page Facebook: បេឡាជាតិរបបសន្តិសុខសង្គម